ZUELLIG PHARMA

making healthcare more accessible



# ក្រមសីលធម៌វិជ្ជាជីវៈ

# សាររបស់នាយកប្រតិបត្តិ

កេរ្តិ៍ឈ្មោះរបស់សហគ្រាសZuellig Pharma ដែលជាដៃគូថែទាំសុខភាពដ៏សំខាន់សម្រាប់អ្នកពាក់ព័ន្ធរបស់យើងគឺត្រូវបានបង្កើតឡើងដោយផ្អែកលើប្រវត្តិសាស្ត្រដ៏យូរអង្វែង នៃការប្រកាន់ខ្ជាប់នូវកម្រិតស្តង់ដារសីលធម៌ និងវិជ្ជាជីវៈខ្ពស់បំផុត ជាមួយនឹងកេរ្តិ៍ឈ្មោះ ដើម្បីផ្តល់ធានាអោយបាននូវសុចរិតភាព ការជឿទុកចិត្ត និងភាពធន់មិនថមថយ។

កិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីធ្វើយ៉ាងណាឱ្យការថែទាំសុខភាពអាចទៅដល់បុគ្គលគ្រប់រូប គឺមានឥទ្ធិពលនិងសារៈសំខាន់យ៉ាងខ្លាំងដល់អាយុជីវិតរបស់មនុស្ស ជាច្រើននៅក្នុងតំបន់។ វាជាការសំខាន់ណាស់ ដែលមនុស្សគ្រប់រូបត្រូវមានទំនួល ខុសត្រូវផ្ទាល់ខ្លួន ក្នុងការប្រកាន់ខ្ជាប់នូវគុណតម្លៃរបស់យើងនិងគោរពតាម គោលការណ៍និងនីតិវិធីក្នុងការងារដែលយើងបំពេញជារៀងរាល់ថ្ងៃ។វាអនុញ្ញាតឱ្យយើងបន្តផ្តល់ជូននូវអ្វីដែលល្អបំផុត ដល់អ្នកជំងឺ ដៃគូអាជីវកម្ម អតិថិជន និយោជិក និងមន្ត្រីរដ្ឋាភិបាលនៅជុំវិញតំបន់។

ក្រមសីលធម៌របស់ក្រុមហ៊ុនZuellig Pharmaគឺជាការណែនាំមួយដើម្បីជួយអ្នកឱ្យយល់ពីរបៀបដែលអ្នកអាចរស់នៅនិងប្រព្រឹត្តអ្វីមួយឱ្យស្របទៅតាមគុណតម្លៃស្នូលនៃភាពស្មោះត្រង់និងការជឿទុកចិត្ត កិច្ចសហការ ការបង្កើតថ្មី ចំណង់ចំណូលចិត្ត ដើម្បីឆ្ពោះទៅរកឧត្តមភាព និងការរីកចម្រើនផ្ទាល់ខ្លួន។ វាបង្ហាញពីកាតព្វកិច្ចរបស់អ្នកក្នុងការអនុវត្តតាមបទប្បញ្ញត្តិប្រកាន់ខ្ជាប់នូវ គោលការណ៍ដែលបានគូសបញ្ជាក់និងបង្ហាញពីភាពស្មោះត្រង់និងភាពគួរឱ្យជឿ ទុកចិត្តដែលភាគីពាក់ព័ន្ធរបស់យើងបានពឹងផ្អែកលើ។

ខ្ញុំជឿជាក់និងរំពឹងថាអ្នកនឹងបន្តប្រកាន់ខ្ជាប់នូវក្រមសីលធម៌នេះឱ្យបានខ្ពស់ បំផុតនិងបន្តបេសកកម្មរបស់យើងក្នុងការធ្វើឱ្យមានការថែទាំសុខភាពកាន់តែ ងាយស្រួលនិងប្រសើរដូចដែលយើងបានធ្វើអស់រយៈពេលជាច្រើនឆ្នាំមកហើយ។





**JOHN GRAHAM**
នាយកប្រតិបត្តិ
ZUELLIG PHARMA

# មាតិកា


1 សេចក្តីផ្តើម p4

2 ក្រមសីលធម៌វិជ្ជាជីវៈ p5

3 ការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងក្រមនានា p6

4 ការសាកសួរសំណួរ &រាយការណ៍អំពីការបំពាន p7

5 កន្លែងការងារវិជ្ជមាន p9

6 អ្នកជម្ងឺ និងក្រុមអ្នកជម្ងឺ p10

7 ទំនាក់ទំនងរដ្ឋាភិបាល p11

8 អំណោយ បដិសណ្ឋារកិច្ច និងផលប្រយោជន៍ផ្សេងៗ p12

9 ទំនាស់ផលប្រយោជន៍ p13

10 វិភាគទានសប្បុរសធម៌ និងនយោបាយ p14

11 ការផ្សព្វផ្សាយជាសាធារណៈ p15

12 បរិស្ថាន p16

13 អន្តរកម្មជាមួយអ្នកផ្តល់សេវាថែទាំសុខភាព p17

14 ការគ្រប់គ្រងព័ត៌មានសុខភាព p18

15 ការប្រកួតប្រជែងដោយស្មើភាព p19

16 អតិថិជន ភ្ញៀវ & ទំនាក់ទំនងបុគ្គលសំខាន់ផ្សេងទៀត p20

17 ការការពារព័ត៌មានសម្ងាត់ p21

18 ព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន p22

19 ពាណិជ្ជកម្មនៅលើព័ត៌មានខាងក្នុង p23

20 បទប្បញ្ញត្តិពាណិជ្ជកម្មអន្តរជាតិ p24

21 ការថែទាំសុវត្ថិភាពទ្រព្យសម្បត្តិ & សន្តិធិ p25

22 កំណត់ត្រា & និងរបាយការណ៍ហិរញ្ញវត្ថុ p26

ធ្វើរឿងអ្វីដែលត្រឹមត្រូវ p27

1

# សេចក្តីផ្តើម

## *ភាពស្មោះត្រង់ និងសេចក្តីសុចរិត ជាស្តង់ដារដែលត្រូវបង្ហាញរបស់យើង និងជាការទទួលខុសត្រូវរបស់អ្នក*

ក្រមនេះបង្ហាញពីការតាំងចិត្តរបស់យើងក្នុងការក្លាយទៅជាក្រមពលរដ្ឋដ៏ល្អមួយ និងការប្រតិបត្តិកិច្ចការអាជីវកម្មរបស់យើងប្រកបដោយសីលធម៌វិជ្ជាជីវៈ។ គោលបំណងនេះនឹងមិនអាចសម្រេចបានដាច់ខាត លុះត្រាតែបុគ្គលិកម្នាក់ៗទទួលយកការទទួល ខុសត្រូវក្នុងការលើកកម្ពស់សុចរិតភាព និងភាពស្មោះត្រង់។ រាល់សកម្មភាពដែលប៉ះ ពាល់ដល់កេរ្តិ៍ឈ្មោះរបស់យើងត្រូវជៀសវាងដាច់ខាត។ ក្រមសីលធម៌វិជ្ជាជីវៈនេះ បង្កើតនូវអ្វីដែលយើងរំពឹងពីអ្នក។

Q: ក្រមនេះមានវិសាលភាពគ្របដណ្តប់ទីតាំងច្រើនជាងគោលនយោបាយ និងនីតិវិធីមូលដ្ឋានរបស់ខ្ញុំ។ ក្នុងករណីខ្លះ គោលនយោបាយ និងនីតិវិធីមូលដ្ឋានរបស់ខ្ញុំគឺមានភាពលម្អិតជាង។ តើវាមានបញ្ហាដែរឬទេ?

A: ក្រមនេះត្រូវរៀបចំឡើងដើម្បីរៀបរាប់គោលការណ៍ធំៗនៃការអនុវត្តអាជីវកម្មរបស់យើង។ គោលនយោបាយ និងនីតិវិធីមូលដ្ឋានរបស់អ្នក គួរស្របជាមួយនឹងក្រមនេះ ហេតុដូច្នេះអ្នកអាចអនុវត្តឯកសារទាំងពីរនេះបាន។ គោលនយោបាយ ឬនីតិវិធីណាដែលតឹងរឹងជាង គួរត្រូវបានអនុវត្ត។ ប្រសិនបើអ្នកមានសំណួរ អ្នកគួរពិភាក្សាជាមួយប្រធានគ្រប់គ្រង ផ្នែកធនធានមនុស្ស ឬសមាជិកអ្នកគ្រប់គ្រងជាន់ខ្ពស់របស់អ្នក។

យើងមិនអាចដឹងគ្រប់ស្ថានភាពដែលអាចបង្កើតជាបញ្ហាសីលធម៌ និងយល់ថាមិនមែនស្ថានភាពទាំងអស់សុទ្ធតែខ្មៅ និងសនោះទេ។ គន្លឹះក្នុងការអនុលោមជាមួយនឹងក្រមនេះគឺការអនុវត្តការសម្រេចចិត្តដ៏ត្រឹមត្រូវ។ នេះមានន័យថាអនុវត្តតាមស្មារតីនៃក្រមនេះ និងច្បាប់ ដោយធ្វើអ្វីដែល "ត្រឹមត្រូវ និងប្រព្រឹត្តដោយមានសីលធម៌ក្នុងករណីដែលគ្មានច្បាប់ចែង។

បេសកកម្មរបស់យើង គឺដើម្បីធ្វើឱ្យមានការថែទាំសុខភាពកាន់តែងាយស្រួល និងប្រសើរ ហើយវាមានការចាំបាច់ណាស់ក្នុងការចងចាំនូវតម្លៃស្នូល ដែលផ្តល់នូវមូលដ្ឋានសម្រាប់វិធីដែលយើងធ្វើអាជីវកម្មៈសេចក្តីសុចរិត & ការទុកចិត្ត កិច្ចសហប្រតិបត្តិការ ការចង់បានសម្រាប់ភាពល្អឥតខ្ចោះ ការអនុវត្ត និងការរីកចំរើនផ្ទាល់ខ្លួន។ ការបង្កើត តាមរយៈការមិនបោះបង់សេចក្តីសុចរិត ការទុកចិត្តគឺជាចំណុចសំខាន់នៃប្រវត្តិរបស់សហគ្រាស Zuellig Pharma។ យើងត្រូវប្រកាន់យក
សេចក្តីសុចរិត និងភាពទុកចិត្តរបស់យើងដាក់ក្នុងខ្លួនចំពោះរាល់សកម្មភាពទាំងអស់ដែលយើងអនុវត្ត។

ក្រុមហ៊ុនរបស់យើងជាក្រុមហ៊ុនធំ ដែលធ្វើប្រតិបត្តិការក្នុងបរិយាកាសសេដ្ឋកិច្ច នយោបាយ និងវប្បធម៌ជាច្រើនផ្សេងគ្នា។ មានសម្ពាធមួយចំនួនដែលជំរុញឲ្យពួកយើងកាន់តែល្អឡើង។ នៅពេលគោលបំណង និងការរំពឹងទុកត្រូវបានបំពេញគឺការសំខាន់ណាស់ពួកគេត្រូវតែបានបំពេញជានិច្ចនៅក្នុងក្របខណ្ឌតម្លៃរបស់យើង។
ក្រមនេះបានលើកឡើងនូវគោលការណ៍ច្បាប់ធំៗ និងការអនុវត្តសីលធម៌អាជីវកម្ម ដែលយើងធ្វើអាជីវកម្ម។ ក្រមនេះអាចត្រូវបានបំពេញបន្ថែមដោយ តែមិនជំនួស ដោយគោលនយោបាយ និងនីតិវិធីពិស្តារបន្ថែមទៀត។ បុគ្គលគ្រប់រូបដែលតំណាងសហគ្រាស Zuellig Pharma បុត្រសម្ព័ន្ធ និងសាខារបស់ខ្លួន ត្រូវបានរំពឹងថាយល់ដឹង និងអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។ ការរំលោភបំពានក្រមនេះ រួមទាំងការខកខានមិនបានរាយការណ៍អំពីការបំពានធ្ងន់ធ្ងរ នឹងមិនត្រូវលើកលែង ហើយនឹងត្រូវគិតថាជាបញ្ហាវិន័យ ដែលអាចនាំឲ្យមានបណ្តឹងរួមទាំងការបញ្ចប់កិច្ចសន្យា




> “ យើងត្រូវប្រើការវិនិច្ឆ័យល្អ និងសតិសម្បជញ្ញៈ ហើយអនុវត្តស្តង់ដារសីលធម៌ខ្ពស់បំផុតចំពោះអ្វីដែលយើងធ្វើ

2

# ក្រមសីលធម៌វិជ្ជាជីវៈ

*ស្វែងយល់ និងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ*

**Q:** ច្បាប់នៅក្នុងប្រទេសរបស់ខ្ញុំ អនុញ្ញាតឲ្យខ្ញុំធ្វើអ្វីមួយ ដែលត្រូវបានហាមឃាត់ដោយក្រមសីលធម៌វិជ្ជាជីវៈ។ តើខ្ញុំគួរធ្វើដូចម្ដេច?

**A:** យើងទទួលស្គាល់ដោយពេញលេញថា ច្បាប់មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត និងទាមទារឲ្យ និយោជិត និងអ្នកតំណាងសហគ្រាស Zuellig Pharma ត្រូវអនុលោមតាមច្បាប់មូលដ្ឋាន។ ប៉ុន្តែ ក្នុងកម្រិតដែលក្រម នេះទាមទារស្តង់ដារប្រសើរជាង យើងតម្រូវឲ្យអនុវត្តតាមស្តង់ដារទាំងនោះ។ វិធានទូទៅ គឺត្រូវគោរពតាមបទដ្ឋាន ក្រម ស្តង់ដារណាតឹងរឹងជាង។

ក្រមសីលធម៌វិជ្ជាជីវៈនេះផ្ដល់នូវការណែនាំសំខាន់ៗ ដែលអ្នកត្រូវការដើម្បីយល់ដឹងអំពីការទទួលខុសត្រូវរបស់អ្នក រួមទាំងកាតព្វកិច្ចរបស់អ្នកក្នុងការអនុលោមតាមច្បាប់ និងដើម្បីផ្ដល់ប្រឹក្សា ដល់ថ្នាក់គ្រប់គ្រងសហគ្រាស Zuellig Pharma អំពីអ្វីគ្រប់យ៉ាងដែលមិនអនុលោមទៅតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈនេះ។

**តើក្រមសីលធម៌វិជ្ជាជីវៈនេះ អនុវត្តចំពោះ នរណាខ្លះ?**

ក្រមនេះអនុវត្តចំពោះ សហគ្រាស Zuellig Pharma ទាំងអស់ បុត្រសម្ព័ន្ធវិសាខា សាខាពាក់ព័ន្ធ និងរួមទាំងបុគ្គលិកពេញម៉ោង និងក្រៅម៉ោង បុគ្គលិកជាប់កិច្ចសន្យា បុគ្គលិកដៃគូអាជីវកម្ម និងបុគ្គលិកបណ្ដោះអាសន្ន។ ក្រមនេះនឹងអនុវត្តខណៈពេលបំពេញការងារនៅបរិវេណរបស់យើង នៅទីតាំងឆ្ងាយដែលអាជីវកម្មរបស់យើងកំពុងដំណើរការ នៅអាជីវកម្មដែលឧបត្ថម្ភដោយក្រុមហ៊ុន និងព្រឹត្តការណ៍សង្គម ឬនៅទីកន្លែងផ្សេងទៀតដែលអ្នកគឺជាតំណាងរបស់ក្រុមហ៊ុន។

**ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ៖**

- យល់ដឹងអំពីក្រមនេះ
- អនុវត្តអាជីវកម្មសហគ្រាស Zuellig Pharma ទាំងអស់ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងគោលនយោបាយរបស់ក្រុមហ៊ុន រួមទាំងក្រមនេះផង
- ការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ ឬក្រមនេះ និងត្រូវរាយការណ៍អំពីការបំពានជានិច្ច
- ជៀសវាងការសម្របសម្រួលសេចក្តី សុចរិតរបស់យើងដើម្បីសម្រេចនូវគោលបំណង
- សួរសំណួរ ឬស្វែងរកការណែនាំពីប្រធានគ្រប់គ្រងរបស់អ្នកនៅពេលមានបញ្ហា។

ប្រធានគ្រប់គ្រងត្រូវធ្វើជាគំរូ សម្រាប់និយោជិតផ្សេងទៀត និងត្រូវទទួលខុសត្រូវក្នុងការណែនាំវិធានការដល់អ្នកដទៃ។ ប្រធានគ្រប់គ្រងម្នាក់ៗត្រូវបានរំពឹងថា ត្រូវចាត់វិធានការណ៍ ចាំបាច់នានា ដើម្បីធានាដល់ការអនុវត្តស្របតាមក្រមនេះ ដោយផ្ដល់នូវការណែនាំ និងជួយដល់និយោជិតក្នុង ការដោះស្រាយបញ្ហាទាក់ទងនឹងក្រមនេះ និងលើកទឹកចិត្តឲ្យនិយោជិតបង្ហាញនូវការបារម្ភរបស់ពួកគេទាក់ទងនឹងការអនុលោមតាមក្រមនេះ។




**ការដោះស្រាយបញ្ហាលំបាកៗ៖**

នៅពេលខ្លះ អ្នកអាចជួប បញ្ហាដែលពិបាកក្នុងការដោះស្រាយ។ ចូរសួរខ្លួនអ្នកអំពីសំណួរទាំងនេះ អំពីរបៀបដែលអ្នកនឹងត្រូវដោះស្រាយវា៖

- តើវាជាបញ្ហាសីលធម៌ ឬបញ្ហាច្បាប់?
- តើវាស្របជាមួយនឹងគោលនយោបាយរបស់យើង និងក្រមនេះឬទេ?
- តើវាស្របជាមួយបេសកកម្ម និងតម្លៃរបស់យើងឬទេ?
- តើខ្ញុំអាចពន្យល់បញ្ហានេះដល់គ្រួសារ និងមិត្តភ័ក្តរបស់ខ្ញុំបានទេ?
- តើខ្ញុំមានអារម្មណ៍ដូចម្ដេច ប្រសិនបើវាត្រូវបានផ្សព្វផ្សាយនៅលើសារព័ត៌មាន?

“ គ្មានបុគ្គលណាម្នាក់ អាចតម្រូវឲ្យនរណាម្នាក់ទៀតអនុវត្តសកម្មភាពដែលផ្ទុយនឹងក្រមនេះបានឡើយ។

3

# ការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងក្រមនានា

*យល់ដឹងអំពីច្បាប់ បទប្បញ្ញត្តិ និងក្រមដែលអនុវត្តចំពោះអ្នក និងសហគ្រាស* **Zuellig Pharma**

**Q:** តើខ្ញុំអាចដឹងថាច្បាប់ និងបទប្បញ្ញត្តិណាខ្លះ ដែលខ្ញុំត្រូវដឹង?

**A:** អ្នកគួរតែពិភាក្សាជាមួយប្រធានគ្រប់គ្រងរបស់អ្នក អំពីច្បាប់ និងបទប្បញ្ញត្តិដែលត្រូវអនុវត្តចំពោះការងាររបស់អ្នក។ម្យ៉ាងវិញទៀត អ្នកក៏ត្រូវពិភាក្សាជាមួយផ្នែកធនធានមនុស្ស ផ្នែកច្បាប់ និងផ្នែកប្រតិបត្តិតាមផងដែរ ដើម្បីធ្វើឲ្យប្រាកដថាអ្នកបានយល់ច្បាស់ពី ច្បាប់ បទប្បញ្ញត្តិ និងក្រមនានា ។

ក្រមនេះបញ្ជាក់បន្ថែមថា យើងតាំងចិត្តក្នុងការអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងក្រមនានា ដើម្បីការពារក្រុមហ៊ុន និងនិយោជិតរបស់ខ្លួន។

យើងតាំងចិត្តអនុវត្តឲ្យបានពេញលេញទៅតាមច្បាប់ បទប្បញ្ញត្តិ និងក្រមជាធរមានទាំងជាលាយលក្ខណ៍អក្សរ និងស្មារតី។ ច្បាប់ បទប្បញ្ញត្តិ និងក្រមជាច្រើន កំណត់ និងបង្កើតនូវកាតព្វកិច្ចនានា ដែលសហគ្រាស Zuellig Pharma,បុគ្គលិកពេញម៉ោង ក្រៅម៉ោង ជាប់កិច្ចសន្យា ឬបុគ្គលិកដៃគូអាជីវកម្ម និងបុគ្គលិកបណ្តោះអាសន្នរបស់ខ្លួន ត្រូវអនុវត្តតាម។ ការបំពានច្បាប់ បទប្បញ្ញត្តិ និងក្រមអាចនាំឲ្យសហគ្រាស Zuellig Pharma, មានផលវិបាកធ្ងន់ធ្ងរ ដូចជាការដាក់ទណ្ឌកម្មផ្នែកច្បាប់ និងហិរញ្ញវត្ថុ ការខូចខាតផ្នែកស៊ីវិល ការកាត់ទោសព្រហ្មទណ្ឌ និងបំផ្លាញនូវកេរ្តិ៍ឈ្មោះរបស់ខ្លួន។

**តើយើងត្រូវអនុវត្តច្បាប់អ្វីខ្លះ?**

យើងត្រូវអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងក្រមទាំងអស់នៅក្នុងប្រទេសទាំងអស់ ដែលតម្រូវសម្រាប់សហគ្រាស អាជីវកម្ម និងនិយោជិតទាំងអស់។ និយោជិតទាំងអស់ត្រូវមានចំណេះដឹង អំពីច្បាប់ បទប្បញ្ញត្តិ និងក្រមដែលអនុវត្តចំពោះការងាររបស់ខ្លួន និងត្រូវសួរប្រធានគ្រប់គ្រងរបស់ខ្លួន ប្រសិនបើខ្លួនមានសំណួរ។

**ឧទាហរណ៍មួយចំនួននៃច្បាប់ដែលអនុវត្តចំពោះអ្នក៖**

- អំពើពុករលួយ
- បរិស្ថាន
- ការការពារទិន្នន័យ និងភាពឯកជន
- ការប្រកួតប្រជែង
- ការងារ
- ការធ្វើពាណិជ្ជកម្មខាងក្នុង
- ប្រឆាំងការលាងលុយកខ្វក់
- ការដាក់ទណ្ឌកម្មអន្តរជាតិ
- ការថែទាំសុខភាព

> ត្រូវសាកសួរជានិច្ច ប្រសិនបើអ្នកមិនច្បាស់អំពីការអនុលោមតាម ច្បាប់ បទប្បញ្ញត្តិ និងក្រមនិងតម្រូវការផ្លូវច្បាប់ផ្សេងៗ។





**ប្រសិនបើយើងមិនអនុវត្តតាមច្បាប់ តើនឹងមានអ្វីកើតឡើង?**

ការរំលោភបំពានច្បាប់ ឬបទប្បញ្ញត្តិ អាចបង្កើតជាការទទួលខុសត្រូវព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីផ្ទាល់ខ្លួន។ អ្នកក៏អាចត្រូវទទួលទណ្ឌកម្មផ្នែកវិន័យផងដែរ ដែលអាចនាំទៅដល់ការបាត់បង់ការងារ។ អ្នកក៏អាចធ្វើឲ្យសហគ្រាស Zuellig Pharma, មានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីផងដែរ។

4

# ការសាកសួរសំណួរ & រាយការណ៍អំពីការបំពាន

*អ្នកមានករណីយកិច្ចត្រូវរាយការណ៍*

**តើខ្ញុំត្រូវធ្វើបែបណាប្រសិនបើខ្ញុំគិតថាការរំលោភបំពានបានកើតឡើង?**

តាមក្រមនេះ ប្រសិនបើអ្នកជឿថាការរំលោភបំពានបានកើតឡើង ឬអ្នកបានធ្វើការរំលោភបំពានហើយនេះគឺផ្ទុយពីក្រមអ្នកត្រូវតែពិភាក្សាជាមួយអ្នកគ្រប់គ្រងរបស់អ្នកជាមុន។ អ្នកគ្រប់គ្រងរបស់អ្នកមានកាតព្វកិច្ច ធ្វើសកម្មភាពដោះស្រាយបញ្ហាឬបញ្ឈប់វា។ ប្រសិនបើអ្នកបានពិភាក្សាជាមួយអ្នកគ្រប់គ្រងរបស់អ្នក ប៉ុន្តែអ្នកមានអារម្មណ៍ថា បញ្ហាមិនទាន់ដោះស្រាយ ឬការរំលោភបំពានពាក់ព័ន្ធនឹងអ្នកគ្រប់គ្រងរបស់អ្នកហើយ អ្នកមិនហ៊ានពិភាក្សាអំពីវាជាមួយអ្នកគ្រប់គ្រងរបស់អ្នក អ្នកអាចទាក់ទងថ្នាក់លើរបស់ អ្នកគ្រប់គ្រងរបស់អ្នក មន្ត្រីអនុវត្តច្បាប់ ឬអ្នកគ្រប់គ្រងទូទៅ។

**តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនហ៊ាននិយាយជាមួយអ្នកគ្រប់គ្រង ឬពួកគេមិនបានដោះស្រាយបញ្ហា?**

យើងលើកទឹកចិត្តអ្នកក្នុងការនិយាយដោយប្រើបណ្តាញទាក់ទងដែលបានផ្តល់ឲ្យអ្នក(មើលទំព័របន្ទាប់)។ និយាយតាម ប្រព័ន្ធរាយការណ៍តាមទូរស័ព្ទ ត្រូវបានរៀបចំដោយពឹងពាក់ទៅលើភាគីទីបីដែលមានភាពឯករាជ្យហើយនឹងមិនត្រូវបានគេលួចស្តាប់ឬថតទុកទេ។ ការនិយាយតាមប្រព័ន្ធរាយការណ៍តាមទូរស័ព្ទ អនុញ្ញាតឲ្យអ្នកនិយាយពី ការព្រួយបារម្ភរបស់អ្នកដោយសម្ងាត់និងអនាមិក។ តតិយជន នឹងបញ្ជូនការព្រួយបារម្ភណ៍របស់អ្នកទៅក្រុមអ្នកអនុវត្តច្បាប់ដោយមិនប្រាប់ឈ្មោះរបស់អ្នកប្រសិនបើអ្នកជ្រើសរើសអនាមិក។

> អ្នកមានកាតព្វកិច្ចសួរនិងរាយការណ៍ ពីការរំលោភបំពានផ្ទាល់ឬការសង្ស័យសម្រាប់ក្រមនេះដើម្បីឲ្យយើងធ្វើឲ្យក្រុមហ៊ុនកាន់តែប្រសើរឡើង។ សកម្មភាពរបស់អ្នកអាចធ្វើឲ្យមានការផ្លាស់ប្តូរ។

**តើខ្ញុំគួរតែព្យាយាមស៊ើបអង្កេតដោយខ្លួនឯង?**

កុំព្យាយាម ស៊ើបអង្កេតឬដោះស្រាយបញ្ហាដោយខ្លួនឯង។ កាតព្វកិច្ចរបស់អ្នកគឺរាយការណ៍ពីការរំលោភបំពាន ឬការព្រួយបារម្ភណ៍។ យើងយកចិត្តទុកដាក់លើការរាយការណ៍របស់អ្នកហើយនឹង ស៊ើបអង្កេតរាល់ការរំលោភបំពានរបាយការណ៍និងការព្រួយបារម្ភណ៍។ សូមទុកពត៏មានសម្រាប់ទាក់ទងអ្នកប្រសិនបើអ្នកអាចទុកបានហើយនឹង សហប្រតិបត្តការណ៍ជាមួយការ ស៊ើបអង្កេតយ៉ាងពេញលេញ។

**តើខ្ញុំនឹងមានបញ្ហាដែរឬទេ ប្រសិនបើខ្ញុំរាយការណ៍ពីការរំលោភបំពាន?**

គ្មានការសងសឹកណានឹងកើតមានទៅលើអ្នកដែលរាយការណ៍ពីការចោទប្រកាន់លើការរំលោភបំពានចែងក្នុងច្បាប់ ឬគោលនយោបាយរបស់ក្រុមហ៊ុនរួមទាំងនៅក្នុងក្រមនេះ។ នរណាម្នាក់ដែលសងសឹកអាចទុកជាការទួលខុសត្រូវ រដ្ឋប្បវេណី ព្រហ្មទណ្ឌ និងការពិន័យរដ្ឋបាល ក៏ដូចជាការពិន័យជាសកម្មភាពនិងរួមបញ្ចូលទាំងការបញ្ឈប់ពីការងារ។ ត្រូវចាំថាអ្នកមានជំរើសក្នុងការប្រើការនិយាយតាមប្រព័ន្ធរាយការណ៍តាមទូរស័ព្ទ អ៊ីមែល វិបសាយ ដែលផ្តល់ឲ្យដោយ ភាគីទីបីឯករាជ្យ ប្រសិនបើអ្នកមិនហ៊ានពិភាក្សាការចោទប្រកាន់ពីការរំលោភបំពានជាមួយអ្នកគ្រប់គ្រងតាមប្រទេសឬតំបន់ ហើយអ្នកអាចធ្វើវាដោយអនាមិក។

**តើអ្នកណាដែលខ្ញុំគួរតែសួរទាក់ទងទៅនឹងក្រមនេះ?**

អ្នកគួរតែប្រាប់ទៅអ្នកគ្រប់គ្រងរបស់អ្នកជាមុន។ ប៉ុន្តែប្រសិនបើអ្នកមិនហ៊ាននិយាយ ជាមួយអ្នកគ្រប់គ្រងរបស់អ្នកទេ អ្នកអាចនិយាយជាមួយថ្នាក់លើរបស់អ្នកគ្រប់គ្រងរបស់អ្នក ផ្នែកប្រតិបត្តិតាមផ្នែកធនធានមនុស្ស ឬប្រធានគ្រប់គ្រងជាន់ខ្ពស់របស់អ្នក។

**ចំណាំ៖** ផ្នែកធនធានមនុស្សក្នុងតំបន់របស់អ្នកអាចឲ្យអ្នកនូវឯកសារបកប្រែស្ដីពីក្រមនេះ។ ប៉ុន្តែសូមចងចាំថាឯកសារជាភាសា អង់គ្លេសមានប្រសិទ្ធិភាពជាង។

# តើត្រូវរាយការណ៍ពីការរំលោភបំពាននៃក្រមនេះដោយ?របៀបណា

## ប្រើបណ្តាញនិយាយដែលមាននៅខាងក្រោម៖

អ្នកអាចធ្វើការរាយការណ៍តាមការនិយាយតាមបណ្តាញ ដោយប្រើវែបសាយ អ៊ីមែល ឬការហៅទូរស័ព្ទមិនគិតលុយជាភាសាអង់គ្លេស ឬជាភាសារបស់អ្នក។ រាល់របាយការណ៍អាចត្រូវបានធ្វើដោយអនាមិក។

### វែប៖

**zuelligpharma.ethicspoint.co**
អ្នកនឹងត្រូវបានផ្តល់ឲ្យនូវជំរើសដើម្បីជ្រើសរើសភាសាអង់គ្លេស ឬភាសាតំបន់របស់អ្នក។

### អ៊ីមែល៖

**zpspeakup@zuelligpharma.com**

### ការហៅទូរស័ព្ទមិនគិតលុយ៖

លេខទូរស័ព្ទសម្រាប់ប្រទេសយើងទាំងអសអាចរកបាននៅគេហទំព័ www.zuelligpharma.com/about-us/ethics-compliance ។ លើសពីនេះទៀត លេខទូរស័ព្ទសម្រាប់ប្រទេសរបស់អ្នក ត្រូវបានបង្ហាញនៅគ្រប់កន្លែងទាំងអស់របស់ Zuellig Pharma ។

ការហៅនឹងត្រូវបានឆ្លើយដោយអ្នកផ្តល់ hotline ឯករាជ នៅពេលអ្នកហៅ សូមប្រាប់ពួកេគថាអ្នកមកពីសហហគាស Zuellig Pharma ។ ប្រសិនបើអ្នកមិនចេះនិយាយភាសាអង់គ្លេស សូមស្នើទៅអោយ អ្នកបកប្រែចូលរួមការហៅនេះ។ ស ូ មកុំបិទទូរស័ព្ទ ព្រោះការរាយការណ៍របស់អ្នកគឺសំខាន់ខ្លាំង ណាស់។



# 5

# កន្លែងការងារវិជ្ជមាន

*យើងម្នាក់ៗមានសិទ្ធិបំពេញការងារក្នុងបរិយាកាសសុវត្ថិភាព និង គោរពគ្នាទៅវិញទៅមក*

**Q:** មិត្តភ័ក្ររបស់ខ្ញុំម្នាក់ធ្វើរឿងកំប្លែងមកកាន់ក្រុមរបស់យើង។ រឿងកំប្លែងតែងតែមានពាក់ព័ន្ធរឿងផ្លូវភេទ និងធ្វើឲ្យខ្ញុំ និងសមាជិកក្រុមតូចចិត្ត។ តើខ្ញុំគួរធ្វើដូចម្តេច?

**A:** ស្នើឲ្យបុគ្គលនោះបញ្ឈប់ការផ្ញើសារបែបនេះទៀត និងរាយការណ៍អំពីករណីនេះទៅកាន់ប្រធានគ្រប់គ្រង ឬផ្នែកធនធានមនុស្សរបស់អ្នក។ ការផ្ញើរឿងកំប្លែងដែលពាក់ព័ន្ធនឹងពូជសាសន៍ ផ្លូវភេទ ឬបទល្មើសផ្សេងៗគឺជាទម្រង់មួយនៃការរុកគួន ហើយដែលមិនអាចអត់ឱនឲ្យបានឡើយ។

ក្រមនេះកំណត់ពីបែបបទដែលយើងរក្សាកាតព្វកិច្ចសីលធម៌របស់យើង ដើម្បីប្រព្រឹត្តចំពោះមនុស្សដោយសេចក្តីសុច្ចរិត។ ដោយការបង្កើតកន្លែងការងារវិជ្ជមាន យើងនឹងអាចជួល និងរក្សាបានបុគ្គលិកល្អៗ និងមានកម្លាំងបំពេញការងារយ៉ាងសកម្ម។

បុគ្គលិករបស់យើងត្រូវតម្រូវឲ្យបង្កើត និងរក្សាបរិយាកាសការងារ ដែលឆ្លើយតបទៅតម្លៃស្នូល របស់ក្រុមហ៊ុន។ បុគ្គលិកទាំងអស់ត្រូវប្រព្រឹត្តដាក់គ្នាទៅវិញទៅមកដោយស្មោះត្រង់ បើកចំហ និងជឿទុកចិត្ត។ បុគ្គលិកទាំងអស់ត្រូវទទួលខុសត្រូវចំពោះការរក្សាសេចក្តីថ្លៃថ្នូរកម្រិតខ្ពស់បំផុត និងគោរពចំពោះអ្នកដទៃ។ ការគោរពក៏មានន័យថា ផ្តល់តម្លៃដល់ភាពខុសគ្នា និងមតិរបស់គ្នាទៅវិញទៅមក និងមិនធ្វើបាបអ្នកដទៃដោយការរំខាន ឬគំរាមកំហែងឡើយ។

**ការរើសអើង & ការរុកគួន**

មិនត្រូវរើសអើង ដោយផ្អែកលើពូជសាសន៍ សាសនា ភេទ និន្នាការភេទ អាយុ ដើមកំណើតជាតិ ពិការភាព ឬស្ថានភាពអាពាហ៍ពិពាហ៍។ មនុស្សគ្រប់រូបមានទំនួលខុសត្រូវ ក្នុងការធានាថាការរើសអើង និងការយាយីដោយខុសច្បាប់ រួមទាំងការយាយីផ្លូវភេទ មិនត្រូវបានអត់អោននៅក្នុងកន្លែងធ្វើការរបស់យើង ហើយក៏មិនមែនជាផ្នែកមួយនៃការសម្រេចចិត្តទាក់ទងនឹងការងារដូចជា៖

- ការជ្រើសរើសបុគ្គលិក
- ការបណ្តុះបណ្តាល
- ការជួលបុគ្គលិក
- ការដាក់វិន័យ
- សំណងនានា
- ការតម្លើងឋានៈ

ប្រសិនបើអ្នកមានសំណួរអំពីការរើសអើង និងការធ្វើទុក្ខបុកម្នេញ សូមទាក់ទងមកកាន់ប្រធានគ្រប់គ្រងរបស់អ្នក ឬផ្នែកធនធានមនុស្ស។



> បុគ្គលិកម្នាក់ៗត្រូវតែទទួលបានការគោរព និងសេចក្តីថ្លៃថ្នូរនៅកន្លែងការងារ។

**សុវត្ថិភាពកន្លែងការងារ**

យើងក៏ប្តេជ្ញាផ្តល់នូវបរិយាកាសសុវត្ថិភាព និងអនាម័យ ដែលឲ្យបុគ្គលិកម្នាក់ៗអាចធ្វើកិច្ចការ ឲ្យមានប្រសិទ្ធិភាព និងមានផលិតផល។ សុវត្ថិភាពនិយោជិតគឺជាអាទិភាពចម្បងបំផុត ហើយយើងធ្វើការ ដោយការព្យាយាមក្នុងការការពារសុខភាព និងសុវត្ថិភាពកម្លាំងពលកម្មរបស់យើង ដោយធានាការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធិភាព និងវិធានការការពារ នៅកន្លែងបំពេញការងារ។ បុគ្គលិកម្នាក់ត្រូវតម្រូវឲ្យអនុវត្ត និងគាំទ្រដល់គោលនយោបាយសុត្ថិភាព។

**ការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង**

ការប្រើប្រាស់ លក់ មាន ឬធ្វើការក្រោមឥទ្ធិពលនៃគ្រឿងញៀន ឬគ្រឿងស្រវឹងខុសច្បាប់នៅ Zuellig Pharma ត្រូវហាមឃាត់។

**ភាពឯកជនរបស់និយោជិក**

ការពារភាពឯកជនរបស់មនុស្សគ្រប់រូបជានិច្ចកាល។ Zuellig Pharma គោរពព័ត៌មានផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិរបស់និយោជិក។ ការទទួលបានព័ត៌មានផ្ទាល់ខ្លួន ឬទ្រព្យសម្បត្តិរបស់និយោជិកត្រូវបានអនុញ្ញាតសម្រាប់តែបុគ្គលិកសមរម្យដែលមានហេតុផលត្រឹមត្រូវក្នុងការទទួលបានព័ត៌មាន ឬទ្រព្យសម្បត្តិនោះ។

6

# អ្នកជម្ងឺ និងក្រុមអ្នកជម្ងឺ

*យើងចាត់ទុកអ្នកជម្ងឺ និងក្រុមអ្នកជម្ងឺជាអ្នកចូលរួមយ៉ាងសំខាន់ម្នាក់របស់* ***Zuellig Pharma*។**

ក្នុងនាមជាក្រុមហ៊ុន យើងខិតខំគាំទ្រអ្នកជំងឺតាមរយៈកម្មវិធីប្រកាន់ខ្ជាប់របស់អ្នកជំងឺ ថ្នាំដែលមានតំលៃសមរម្យ ការគ្រប់គ្រងជំងឺ និងដំណោះស្រាយថែទាំអ្នកជំងឺដទៃទៀត ក្នុងគោលបំណងធ្វើអោយប្រសើរឡើងនូវសុខភាពអ្នកជម្ងឺ និងផ្តល់នូវគុណភាពជីវិតកាន់តែប្រសើរ។ Zuellig Pharma បានប្តេជ្ញាចិត្តធ្វើការជាមួយក្រុមអ្នកជំងឺ ដើម្បីបង្កើនការយល់ដឹងរបស់យើង អំពីអ្នកជំងឺ និងតម្រូវការរបស់ពួកគេអោយកាន់តែស៊ីជម្រៅនៅពេលដែលយើងផ្តល់ជូនសេវាកម្មអប់រំ និងគាំទ្រដល់អ្នកជំងឺនៅតាមតំបន់ព្យាបាលផ្សេងៗ។

និយោជិកម្នាក់ៗ ត្រូវបានគេរំពឹងថានឹងប្រកាន់ខ្ជាប់នូវចំណុចខាងក្រោមនៅពេលទាក់ទងជាមួយអ្នកជំងឺ៖

- មានតែបុគ្គលិក / បុគ្គលិកដែលមានការអនុញ្ញាត និងមានការយល់ព្រម ប៉ុណ្ណោះដែលអាចធ្វើអន្តរកម្មជាមួយអ្នកជំងឺបាន
- អ្នកតំណាងផ្នែកលក់ មិនត្រូវបានអនុញ្ញាតឱ្យធ្វើអន្តរកម្មជាមួយអ្នកជំងឺ ឬអ្នកថែទាំដែលមានការអនុញ្ញាតរបស់ពួកគេឡើយ
- មានតែអ្នកជំងឺដែលគ្រូពេទ្យចុះឈ្មោះ ក្នុងកម្មវិធី Zuellig Pharma ដែលបានចុះហត្ថលេខាលើទម្រង់យល់ព្រមរបស់អ្នកជំងឺប៉ុណ្ណោះដែលអាចចូលរួមបាន

និយោជិកទាំងអស់ ត្រូវបានគេរំពឹងថា នឹងរក្សានូវក្រមសីលធម៌ខ្ពស់បំផុត ក្នុងការទំនាក់ទំនងជាមួយក្រុមអ្នកជំងឺ។ ដូច្នេះ ការគោរពឯករាជ្យភាពរបស់ពួកគេ ជាក្រុមមួយដោយគ្មានឥទ្ធិពលហួសហេតុ។ នៅពេលធ្វើការជាមួយក្រុមអ្នកជម្ងឺ បរិបទនៃការចូលរួមរបស់ក្រុមហ៊ុន គួរតែត្រូវបានចងក្រងជាឯកសារនិងច្បាស់លាស់នៅគ្រាដំបូង។

ការធ្វើអន្តរកម្មជាមួយអ្នកជំងឺ និងក្រុមអ្នកជំងឺត្រូវតែអនុវត្តតាមច្បាប់បទប្បញ្ញត្តិ និងក្រមដែលពាក់ព័ន្ធទាំងអស់របស់រដ្ឋាភិបាល រួមទាំងគោលការណ៍ណែនាំសមាគមឧស្សាហកម្មឱសថនិងគោលនយោបាយ Zuellig Pharma។

ប្រសិនបើអ្នកមានសំណួរអំពីរបៀបដោះស្រាយជាមួយក្រុមអ្នកជំងឺ និងក្រុមអ្នកជម្ងឺ អ្នកគួរតែស្វែងរកជំនួយពីអ្នកគ្រប់គ្រងផ្នែកវេជ្ជសាស្ត្រនិង/ឬផ្នែកប្រតិបត្តិតាមក្នុងស្រុករបស់អ្នក។

### សំណួរទី1

**Q:** តើយើងអាចបង្កើតកម្មវិធីដែលនឹងគាំទ្រដល់ក្រុមអ្នកជម្ងឺ ហើយជាថ្នូរមកវិញ យើងនឹងប្រើវាដើម្បីគាំទ្រឬផ្សព្វផ្សាយផលិតផលរបស់យើងដែរឬទេ?

**A:** ទេ។ អន្តរកម្មណាមួយជាមួយក្រុមអ្នកជម្ងឺមិនគួរមានបំណងជះឥទ្ធិពលដល់ពួកគេទេ។

### សំណួរទី2

**Q:** ក្នុងអំឡុងពេលព្រឹត្តិការណ៍មួយជាមួយអ្នកជំងឺ យើងបានប្រមូលព័ត៌មានរបស់ពួកគេ (ឈ្មោះនិងលេខទំនាក់ទំនង) ដូច្នេះ យើងអាចបញ្ជូនឯកសារអំពីផលិតផលដែលមានលក្ខណៈក្រមសីលធម៌ / វេជ្ជបញ្ជារបស់យើង។ តើនេះត្រូវបានអនុញ្ញាតទេ?

**A:** ទេ។ ការធ្វើអន្តរកម្មជាមួយអ្នកជម្ងឺ និងក្រុមអ្នកជម្ងឺដោយមានគោលបំណងផ្សព្វផ្សាយដើម្បីណែនាំ និងចេញវេជ្ជបញ្ជាឱសថផ្សេងៗ / ផលិតផលវេជ្ជបញ្ជា ត្រូវបានហាមឃាត់។



> ក្រុមហ៊ុនត្រូវគោរពសិទ្ធិរបស់អ្នកជំងឺ ចំពោះភាពឯកជន និងការសម្ងាត់នានា

7

# ទំនាក់ទំនងរដ្ឋាភិបាល

*ធ្វើអាជីវកម្មជាមួយរដ្ឋាភិបាល*

Q: ខ្ញុំមានសាច់ញាតិធ្វើការនៅមន្ទីរពេទ្យរដ្ឋាភិបាល ដែលអាច ជួយពួកយើងឲ្យយកឈ្នះការដេញថ្លៃសម្រាប់ជាអតិថិជន ម្នាក់ក្នុងចំណោមអតិថិជនរបស់យើង។ គាត់បាននិយាយថា គាត់អាចជួយ "ក្រៅផ្លូវការ" ឥទ្ធិពលគណៈកម្មការដេញថ្លៃ របស់មន្ទីរពេទ្យ ហើយគាត់មិនចង់បានអ្វីពីយើងវិញទេ។
តើការធ្វើដូច្នេះយ៉ាងដូចម្តេចដែរ?

A: សហគ្រាស Zuellig Pharma ធ្វើជំនួញដោយសេចក្តីសុច្ចរិត ត្រឹមត្រូវ និងតម្លាភាព។ អ្នកត្រូវបដិសេធសំណើរបស់សាច់ញាតិរបស់អ្នកដោយសុភាពរាបសារ ព្រោះវាអាចបង្ហាញឲ្យ ឃើញនូវការពាក់ព័ន្ធមិនត្រឹមត្រូវដល់មន្ត្រីរដ្ឋាភិបាល។

> ត្រូវអនុវត្តសីលធម៌ វិជ្ជាជីវៈខ្ពស និងស្តង់ដារគតិយុត្តជានិច្ច នៅពេលដោះស្រាយជា មួយបុគ្គលិករដ្ឋាភិបាល អតិថិជន និងមន្ត្រី។

វាជាការចាំបាច់ ដែលត្រូវធានានូវទំនាក់ទំនងរបស់យើងជាមួយរដ្ឋាភិបាលឲ្យបើកចំហ តម្លាភាព និងមិនត្រូវបំពានច្បាប់ប្រឆាំងអំពើពុករលួយ។

ក្រមនេះលើកឡើងនូវវិធីសាស្ត្ររបស់យើងក្នុង ការដោះស្រាយជាមួយមន្ត្រីរដ្ឋាភិបាល និងទីភ្នាក់ងារបទប្បញ្ញត្តិ និងសហគ្រាសគ្រប់គ្រងដោយរដ្ឋ។ យើងផ្តល់តម្លៃទំនាក់ទំនងល្អប្រសើររបស់យើងជាមួយរដ្ឋាភិបាល ហើយនិងធ្វើដោយយុត្តិធម៌ និងស្មោះត្រង់ជាមួយពួកគេ។ ដំណោះស្រាយ ជាមួយមន្ត្រីរដ្ឋាភិបាល តម្រូវឲ្យមានការពិចារណារ និងថែទាំជាពិសេស ដែលជាពិសេសនោះគឺនៅពេលអ្នកទទួល ឬផ្តល់អំណោយ ឬបដិសណ្ឋារកិច្ច។ ដូច្នេះអ្នកត្រូវយល់ថាអ្វីដែលអ្នកអាច ឬមិនអាចធ្វើ នៅក្រោមផ្នែកស្តីពីអំណោយ បដិសណ្ឋារកិច្ច និង អត្ថប្រយោជន៍ផ្សេងទៀតនៃក្រមនេះ។

**ដំណោះស្រាយជាមួយមន្ត្រីរដ្ឋាភិបាល**

អ្នកមិនត្រូវធ្វើការបង់ប្រាក់ ឬផ្តល់វត្ថុមានតម្លៃផ្សេងទៀតណា (រួមមានអំណោយ បដិសណ្ឋារកិច្ច ឬសន្យា ឬ ផ្តល់វត្ថុមានតម្លៃ) ដោយផ្ទាល់ ឬមិនផ្ទាល់ដល់មន្ត្រីរដ្ឋាភិបាលសម្រាប់គោលបំណងទទួលបាន ឬរក្សានូវអាជីវកម្ម ឬធានានូវអត្ថប្រយោជន៍មិនសមស្របឡើយ។

អ្នកក៏មិនត្រូវធ្វើការបង់ប្រាក់សម្រួលណាមួយដល់មន្ត្រីរដ្ឋាភិបាល ឬបុគ្គលិកដើម្បីពន្លឿនចំណាត់ការរដ្ឋាភិបាល ដែលពួកគេត្រូវតែអនុវត្តនោះដូចជាការដំណើរការឯកសារនានា។ ការចំណាយទាំងនេះក៏អាចហៅថាការទូទាត់មិនសមស្រប "ខ្លាញ់"។

**ឧទាហរណ៍ខ្លះនៃមន្ត្រីរដ្ឋាភិបាលៈ**

- មន្ត្រី ឬបុគ្គលិកមន្ទីររដ្ឋាភិបាល ឬវិទ្យាស្ថានថែទាំសុខភាពរបស់រដ្ឋាភិបាល (ដូចជាមន្ត្រីលទ្ធកម្ម)
- មន្ត្រី ឬបុគ្គលិកនៃភ្នាក់ងាររដ្ឋាភិបាល ឬអាជ្ញាធរនិយ័តកម្ម (ដូចជាក្រសួងសុខាភិបាល គយ ពន្ធដា រដ្ឋបាលឱសថ និងអាហារមូលដ្ឋាន។ល។
- បេក្ខជននយោបាយ ឬសមាជិកបក្សនយោបាយ។
- មន្ត្រីរដ្ឋាភិបាលដែលបំពេញការងារក្នុងសមត្ថភាពសម្រាប់សហគ្រាសពាណិជ្ជកម្ម។

**ហេតុអ្វីបានជាបញ្ហានេះមានសារសំខាន់?**

វាគឺជាគោលនយោបាយរបស់ក្រុមហ៊ុន ក្នុងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមា នស្តីអំពីការទំនាក់ទំនង និងដំណោះស្រាយជាមួយមន្ត្រីរដ្ឋាភិបាលដើម្បីទទួលនូវសីលធម៌ វិជ្ជាជីវៈខ្ពស់ និងស្តង់ដារគតិយុត្ត។

**មិនត្រូវ**

- កត់ត្រាមិនសមស្របនូវរាល់ការទូទាត់ចំពោះភ្នាក់ងាររដ្ឋាភិបាល។
- ប្រើប្រាស់តតិយជន ទីប្រឹក្សា ឬភ្នាក់ងារដើម្បីបំពេញនូវអ្វីដែលយើងមិនអាចធ្វើដោយស្របច្បាប់ និងត្រឹមត្រូវ។

8

# អំណោយ បដិសណ្ឋារកិច្ច និងផលប្រយោជន៍ផ្សេងៗ

*ត្រូវប្រកាន់ជានិច្ចអំណោយត្រូវបដិសេធដោយពាក្យគួរសម និងការប្រគល់អំណោយត្រូវបានការអនុញ្ញាតយល់ព្រមជាមុន*

ដើម្បីរក្សាស្តង់ដារសីលធម៌របស់យើង និងបំពេញតាមកាតព្វកិច្ចរបស់យើងពាក់ព័ន្ធនឹងច្បាប ស្តីពីការប្រឆាំងអំពើពុករលួយ។ និយោជិកទាំងអស់ ត្រូវតែជានាថាអំណោយ បដិសណ្ឋារកិច្ច និងអត្ថប្រយោជន៍ផ្សេងទៀតមិនត្រូវបានផ្តល់ឱ្យ ដោយមានឥទ្ធិពលមិនសមរម្យដល់អន្តរកម្ម របស់យើងជាមួយភាគីទីបីឡើយ។ អ្នកមិនត្រូវផ្តល់ឲ្យ ស្នើសុំវត្ថុមានតម្លៃណាមួយ ដែលអាចជះឥទ្ធិពល ឬបង្ហាញនូវឥទ្ធិពល ទំនាក់ទំនងអាជីវកម្មដោយការអនុវត្តរវាងអ្នក និងភាគីម្ខាងទៀតឡើយ។

លើសពីនេះទៀត វាជាគោលនយោបាយរបស់ Zuellig Pharma ដែលការទទួលយកអំណោយពីភាគីទីបីត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង។

យើងទទួលស្គាល់ថា ការផ្តល់អំណោយ និងបដិសណ្ឋារកិច្ច គឺមានជាទូទៅសម្រាប់ អាជីវកម្មធម្មតា ឬការអនុវត្តនៃវប្បធម៌ដើម្បីពង្រឹង និងបង្កើនទំនាក់ទំនងយូរអង្វែង។ ការផ្តល់វត្ថុសម្រាប់ជាការគួរសម (ដូចជាការអញ្ជើញពិសារអាហារពិភាក្សាអំពីអាជីវកម្មមិនថ្លៃពេក និងម្តងម្កាល ឬអំណោយគ្មានតម្លៃជាប្រាក់) ទៅឲ្យ ឬមកពីអតិថិជន ភ្ញៀវ អ្នកផ្គត់ផ្គង់ អ្នកម៉ៅការ និងភាគីផ្សេងទៀតដែលអ្នកធ្វើអាជីវកម្មជាមួយអាចអនុញ្ញាតបានសម្រាប់ស្ថានភាពខ្លះ។ អំណោយ និងបដិសណ្ឋារកិច្ច ទាំងអស់ត្រូវតែ៖

- មានតម្លៃសមរម្យ
- ជាទម្លាប់ធម្មតា
- មានតម្លាភាព និងបើកចំហ
- មិនបង្កើតនូវឥទ្ធិផល ឬទទួលអត្ថប្រយោជន៍មិនស្មើគ្នា
- ដោយការគោរព និងជាទម្លាប់

ប៉ុន្តែសាច់ប្រាក់ ឬអំណោយមានតម្លៃជាសាច់ប្រាក់ (ដូចជាប័ណ្ណជូនពរ វិញ្ញាបនបត្រ និងប័ណ្ណផ្សេងៗ) មិនអាចផ្តល់ ឬទទួលបានឡើយ។

ការប្រព្រឹត្តអំពើពុករលួយជាអំពើខុសច្បាប់ និងជាកម្មវត្ថុនៃការដាក់ទោសព្រហ្មទណ្ឌ។ អ្នកមិនត្រូវផ្តល់សំណូក ប្រាក់សូកប៉ាន់ ឬអត្ថប្រយោជន៍ផ្សេងទៀតទៅបុគ្គលណាម្នាក់ ឬក្រុមហ៊ុនណាមួយដើម្បីទាក់ទាញ ឬទទួលបានអាជីវកម្មឡើយ។

ការណែនាំទាំងនេះអនុវត្តទាំងចំពោះទំនាក់ទំនងសហគ្រាសរដ្ឋ រដ្ឋាភិបាល និងពាណិជ្ជកម្ម។ ការទំនាក់ទំនងជាមួយរដ្ឋាភិបាល តម្រូវឲ្យមានការពិចារណានិងថែទាំជាពិសេស ដែលធានាថា អ្នកយល់អំពីការទទួលខុសត្រូវរបស់អ្នក ក៏ដូចជា ច្បាប់និងបទបញ្ញត្តិក្នុងស្រុក។

តម្លៃ កម្រៃជើងសារ និងការទូទាត់ផ្សេងទៀតទៅទីប្រឹក្សា ភ្នាក់ងារ ឬតតិយជនខាងក្រៅមិនត្រូវប្រើក្នុងគោលបំណងគេចវេសការណែនាំទាំងនេះឡើយ។

ច្បាប់ណាដែលរឹតបន្តឹងជាងត្រូវបានអនុវត្ត ទាក់ទងនឹងអំណោយ និងបដិសណ្ឋារកិច្ចដែលផ្តល់ជូនអ្នកផ្តល់សេវាថែទាំសុខភាពដូចជាការហាមឃាត់មិនឱ្យអំណោយដល់អ្នកផ្តល់សេវាថែទាំសុខភាព។ អ្នកត្រូវទាក់ទងជាមួយប្រធានគ្រប់គ្រងរបស់អ្នក ឬផ្នែកប្រតិបត្តិតាម ប្រសិនបើអ្នកមានសំណួរ ឬកង្វល់អំពីអំណោយ ការកំសាន្ត ឬអត្ថប្រយោជន៍ផ្សេង ឬការណែនាំនេះ។

**Q:** អ្នកផ្គត់ផ្គង់បានផ្ញើអំណោយមួយកន្ត្រកក្នុងថ្ងៃបុណ្យណូអែល មកអ្នកដើម្បីអរគុណអ្នកដែលបានទិញទំនិញនិងសេវាកម្មពីពួកគេ។ តើអ្នកគួរធ្វើដូចម្តេច?

**A:** ភាគីទីបីទាំងអស់ គួរត្រូវបានរំលឹកពីគោលការណ៍នៃការមិនទទួលយកអំណោយ។ ក្នុងករណីនេះអ្នកគួរតែបដិសេធអំណោយមួយកន្ត្រកនោះដោយពាក្យគួរសម ហើយប្រគល់វាទៅតាមអ្នកផ្ញើវិញ។

**អំណោយ ការកំសាន្ត & អត្ថប្រយោជន៍ផ្សេងៗដែលបានផ្តល់ឲ្យភាគីពាណិជ្ជកម្មអាចជាការខុសច្បាប់ផងដែរ។**

**ទំរង់ណាមួយនៃអំណោយ ពីភាគីទីបីត្រូវតែបដិសេធដោយពាក្យគួរសម**

9

# ទំនាស់ផលប្រយោជន៍

## *ត្រូវជៀសវាងជានិច្ចនូវទំនាស់ផលប្រយោជន៍*

**Q:** បងស្រីរបស់ខ្ញុំគឺជាសមាជិកភាគហ៊ុននៃក្រុមហ៊ុនវេចខ្ចប់សម្ភារៈ ធ្វើការដេញថ្លៃសម្រាប់អាជីវកម្មរបស់សហគ្រាស Zuellig Pharma ។ តើស្ថានភាពដូចនេះ អ្នកត្រូវធ្វើដូចម្តេចដែរ?

**A:** ក្រុមហ៊ុនរបស់បងស្រីរបស់អ្នកអាចធ្វើការដេញថ្លៃសម្រាប់អាជីវកម្មរបស់យើង។ ប៉ុន្តែអ្នកត្រូវបង្ហាញទំនាក់ទំនងនេះ ទៅដល់ប្រធានគ្រប់គ្រងរបស់អ្នក និងមិនត្រូវចូលពាក់ព័ន្ធក្នុងនិតិវិធីនៃការដេញថ្លៃនេះឡើយ។

ជួនកាលវាអាចមានអ្វីមួយកើតមាន ដែលធ្វើឲ្យមានទំនាស់ផលប្រយោជន៍រវាងផលប្រយោជន៍របស់អ្នក និងផលប្រយោជន៍របស់សហគ្រាស Zuellig Pharma។ វាចំបាច់ណាស់ដែលអ្នកត្រូវយល់ដឹង ពីស្ថានភាពដែលអាចឲ្យស្ថានភាពនេះកើតមាន និងពីរបៀបនៃការដោះស្រាយ។

យើងសង្ឃឹមយ៉ាងមុតមាំថាអ្នកនឹងអាចជៀសវាងរាល់ស្ថានភាពដែលអាចបង្កើតជាទំនាស់ផលប្រយោជន៍ជាមួយសហគ្រាស Zuellig Pharma។ ទំនាស់ផលប្រយោជន៍អាចកើតមាន នៅពេលដែលផលប្រយោជន៍បុគ្គលជ្រៀតជ្រែកតាមវិធីណាមួយ ឬបង្ហាញពីការជ្រៀតជ្រែក ទៅនឹងផលប្រយោជន៍របស់សហគ្រាស Zuellig Pharma។ ឬម្យ៉ាងទៀតអ្នកមិនត្រូវកេងយកអត្ថប្រយោជន៍ពីការបំពេញការងារជាមួយសហគ្រាស Zuellig Pharma ដើម្បីទទួល ឬអនុវត្តវិធានការណាមួយ ឬមានផលប្រយោជន៍ណាមួយដែលធ្វើឲ្យអ្នកមានការលំបាកក្នុងការអនុវត្តភារកិច្ច ដោយស្មោះត្រង់ និងមានប្រសិទ្ធិភាព ឬជ្រៀតជ្រែក និងជាមួយនឹងការសម្រេចសេចក្តីបំពេញការងាររបស់អ្នក។

ក្នុងករណីដែលអ្នកអាចមានទំនាស់ផលប្រយោជន៍ ជាក់ស្តែង ឬសក្តានុពល អ្នកត្រូវពិភាក្សាបញ្ហាលម្អិតជាមួយប្រធានគ្រប់គ្រងរបស់អ្នកជានិច្ច។ ចូរចងចាំថាត្រូវរាយការណ៍នូវទំនាស់ផលប្រយោជន៍ជាសក្តានុពលដល់ប្រធានគ្រប់គ្រ របស់អ្នក ឬផ្នែកធនធានមនុស្សដើម្បីទទួលបានការយល់ព្រមជាចាំបាច់។ យើងនឹងធ្វើការរួមគ្នាជាមួយអ្នកដើម្បីដោះស្រាយទំនាស់ និងកង្វល់របស់អ្នក។

**ឧទាហរណ៍ខ្លះនៃទំនាស់ផលប្រយោជន៍ជាសក្តានុពល៖**

**ការវិនិយោគ**
កាន់កាប់ការវិនិយោគ (ដោយផ្ទាល់ ឬប្រយោល ជាអ្នកប្រកួតប្រជែង អ្នកផ្គត់ផ្គង់ អតិថិជន អ្នកចែកចាយ ភ្ញៀវ ឬក្រុមហ៊ុនផ្សេងទៀតដែលធ្វើអាជីវកម្មជាមួយសហគ្រាស Zuellig Pharma ដែលអាចបង្ហាញនូវការសម្រេចសេចក្តីរបស់អ្នកមិនត្រឹមត្រូវចំពោះអ្វីដែលជាអត្ថប្រយោជន៍បំផុតរបស់សហគ្រាសZuellig Pharma។

**ការងារ/សេវាកម្មផ្សេងទៀត**
អ្នក ឬ សមាជិកគ្រួសារអ្នកត្រូវបានជ្រើសរើសអោយចូលបម្រើការងារ ផ្តល់សេវាទៅឲ្យ ឬតំណាងឲ្យដៃគូប្រកួតប្រជែង អ្នកផ្គត់ផ្គង់ អតិថិជន អ្នកចែកចាយ ភ្ញៀវ ឬក្រុមហ៊ុនផ្សេងទៀតដែលធ្វើ ឬមានសក្តានុពលក្នុងការធ្វើអាជីវកម្មជាមួយសហគ្រាស Zuellig Pharma។

**ទំនាក់ទំនងបុគ្គល**
ធ្វើអាជីវកម្មជាមួយដៃគូប្រកួតប្រជែង អ្នកផ្គត់ផ្គង់ អតិថិជន អ្នកចែកចាយ ភ្ញៀវ ឬក្រុមហ៊ុនផ្សេងណាមួយដែលត្រូវបានកាន់កាប់ ឬគ្រប់គ្រង ដោយសាច់ញាតិ សមាជិកគ្រួសារ ឬមិត្តភក្តិជិតស្និទ្ធ។

**ការប្រើប្រាស់ទ្រព្យរបស់ សហគ្រាស Zuellig Phama**
ការប្រើប្រាស់ទ្រព្យ ទីកន្លែង សម្ភារ: ចំណេះដឹង ឬបុគ្គលិករបស់សហគ្រាស សម្រាប់អាជីវកម្មផ្សេងណាមួយ
អត្ថប្រយោជន៍ បុគ្គលផ្ទាល់។

**អំណោយ បដិសណ្ឋារកិច្ច វត្ថុមានតម្លៃ**
ការទទួលយកដោយផ្ទាល់ ឬមិនផ្ទាល់ វត្ថុមានតម្លៃណាមួយពីដៃគូប្រកួតប្រជែង អ្នកផ្គត់ផ្គង់ អតិថិជន អ្នកចែកចាយ
ភ្ញៀវ ឬក្រុមហ៊ុនផ្សេងដែលជាពិសេសក្នុងគោលបំណង ឬអាច មានឥទ្ធិពលមិនសមស្របនឹងសេចក្តីសម្រេចអាជីវកម្ម ឬទំនាក់ទំនង។ Zuellig Pharma ហាមដាច់ខាតការទទួលយកអំណោយពីភាគីទីបី។

**ឱកាសអាជីវកម្មរបស់សហគ្រាស Zuellig Pharma**
ចាប់យកអត្ថប្រយោជន៍នៃ ឱកាសប្រកបអាជីវកម្មណាមួយ និងប្រកួតប្រជែងជាមួយសហគ្រាស Zuellig Pharma ដោយការផ្តល់សេវា ទិញ ឬលក់ទ្រព្យសម្បត្តិ ឬបង្វែរឱកាសអាជីវកម្មពីសហគ្រាស Zuellig Pharma ណាមួយដែលសហគ្រាស Zuellig Pharma មាន ឬអាចនឹងមាន ផលប្រយោជន៍។



> អ្នកមានទំនួលខុសត្រូវក្នុងការជៀសវាងស្ថានភាពដែលផលប្រយោជន៍ផ្ទាល់ខ្លួន ជ្រៀតជ្រែកជាមួយនឹងផលប្រយោជន៍របស សហគ្រាស *Zuellig Pharma*។



10

# វិភាគទានសប្បុរសធម៌ និងនយោបាយ

*អាជីវកម្មមែនជានយោបាយ*

ដើម្បីធានាថាយើងផ្តល់តម្លៃ វិនិយោគដោយប្រសិទ្ធិភាព និងមិនផ្តល់វិភាគទានមនុស្សធម៌ ឬនយោបាយដើម្បីទទួលអត្ថប្រយោជន៍មិនសមរម្យ ក្រុមនេះផ្តល់ការណែនាំអំពីរបៀបដែលការបរិច្ចាគប្រភេទទាំងនេះគួរត្រូវបានធ្វើឡើង។

សហគ្រាស Zuellig Pharma ប្តេជ្ញាក្នុងការផ្តល់វិភាគទានវិជ្ជមាននៅក្នុងសហគមន៍ ដែលយើងធ្វើអាជីវកម្ម។ វាអាចជាការផ្តល់តម្លៃចំពោះការចូលរួមក្នុង ជីវិតឯកជននៃសហគមន៍របស់អ្នក ហើយយើងលើកទឹកចិត្តឲ្យអ្នកធ្វើដូច្នេះ។ ជាផ្នែកមួយនៃការតាំងចិត្តនោះ យើងរក្សាកម្មវិធីសុខុមាលភាពអាជីវកម្ម ដើម្បីគាំទ្រអង្គការ និងសកម្មភាពនានានៅក្នុងសហគមន៍ទាំងនោះ។ ទោះបីជាយ៉ាងនេះក្តី យើងមិនគាំទ្របេក្ខជន ឬបក្សនយោបាយ សាសនា ឬអង្គការសម្ព័ន្ធ។

**វិភាគទានផ្នែកនយោបាយ**

ក្រុមហ៊ុនគ្មានមូលនិធិ ឬសេវាកម្មណាសម្រាប់ផ្តល់ឲ្យ ឬចេញដល់បក្សនយោបាយ ឬបេក្ខជនណាម្នាក់សម្រាប់ការិយាល័យសាធារណៈដោយគ្មានការយល់ព្រមជាមុននោះទេ។ បើទោះបីជាបុគ្គលិកត្រូវបានអនុញ្ញាតឲ្យធ្វើវិភាគទានផ្ទាល់ក្តី ក្រុមហ៊ុននឹងមិ នចេញសងសម្រាប់វិភាគទាននោះទេ។

**វិភាគទានសប្បុរសធម៌**

យើងគាំទ្រកម្មវិធីមនុស្សធម៌ជាច្រើន ដោយមានគោលបំណងនៃការប៉ះពាលវិជ្ជមានដល់សុខភាព និងការរស់នៅរបស់មនុស្សនៅទូទាំងអាស៊ី។ វិភាគទានទាំងអស់ត្រូវមានតម្លាភាព និងយល់ព្រមដើម្បីធានាថា ការវិភាគទានរបស់យើងត្រូវបានផ្តល់ដោយច្បាស់លាស់ និងបើកចំហរ ចំពោះអ្នកដែលត្រូវការបំផុត។

**ចូរចងចាំជានិច្ចថា៖**

| | | |
|---|---|---|
| វិភាគទានសម្រាប់កម្មវិធីមនុស្សធម៌ និងនយោបាយទាំងអស់ត្រូវតែមានការយល់ព្រមជាមុន។ | មិនត្រូវយកមូលនិធិ ទ្រព្យសម្បត្តិ ទីកន្លែង ឬពេលបំពេញការងាររបស់បុគ្គលិកក្រុមហ៊ុនទៅប្រើសម្រាប់ ឬផ្តល់ឲ្យការឃោសនាគោលនយោបាយ ឬ ទ្រឹស្តីនយោបាយនៅក្នុងកាលៈទេសៈណាក្តី។ | អ្នកត្រូវមានការប្រយ័ត្នជានិច្ចនៅពេលដែលអ្នកត្រូវបានស្នើឲ្យធ្វើវិភាគទានសម្រាប់មនុស្សធម៌ ឬនយោបាយ នឹងធានាថាការចូលរួមវិភាគទានបែបនេះគឺមិនមានចេតនាមិនត្រឹមត្រូវដើម្បីមានឥទ្ធិពល ឬទទួលបានអត្ថប្រយោជន៍អយុត្តិធម៌ណាមួយឡើយ។ |

Q: តើខ្ញុំអាចប្រមូលប្រាក់នៅកន្លែងការងារសម្រាប់បក្សនយោបាយឬទេ?

A: ជាទូទៅ ការងារស្ម័គ្រចិត្តក្នុងយុទ្ធនាការនយោបាយតាមលទ្ធភាពរបស់ខ្លួនត្រូវបានអនុញ្ញាត។ ក៏ប៉ុន្តែអ្នកមិនអាចធ្វើសកម្មភាពនយោបាយ ដូចជាការប្រមូលប្រាក់នៅកន្លែងការងារបានទេ។



ត្រូវធានាថាការបរិច្ចាគនៅក្នុងសហគមន៍របស់យើងត្រូវតែបើកចំហ និងមានតម្លាភាពជានិច្ច។



11

# ការផ្សព្វផ្សាយជាសាធារណៈ

*បង្ហាញតែព័ត៌មានដែលមានការយល់ព្រមប៉ុណ្ណោះ*

**Q:** ខ្ញុំនឹងបញ្ចេញមតិនៅលើទំព័រ Facebook ឬបណ្តាញសង្គមដទៃទៀតរបស់ខ្ញុំអំពីការសើបអង្កេតលើបុគ្គលិកថ្មីខ្លះ ពីការលួចកម្មសិទ្ធិរបស់ក្រុមហ៊ុន។ តើខ្ញុំនឹងមានបញ្ហាដែរឬទេ?

**A:** អ្នកនឹងមានបញ្ហា។ ការបញ្ចេញមតិអំពីការ សើបអង្កេតរបស់ក្រុមហ៊ុនគឺមិនត្រូវបានអនុញ្ញាតទេតាមក្រមនេះ។ នេះរួម បញ្ចូលទាំងការបញ្ចេញមតិនៅលើទំព័រ Facebook ខ្លួន។

មុខមាត់របស់សហគ្រាស Zuellig Pharma ជាកត្តាដ៏សំខាន់សម្រាប់បង្កើតទំនុកចិត្តដល់បុគ្គលិក រដ្ឋាភិបាល ភ្ញៀវ អតិថិជន ម្ចាស់ភាគហ៊ុនផ្សេងៗ និងសាធារណជន។ ដើម្បីឲ្យប្រាកដថា យើងជឿទុកចិត្តបាន យើងទាំងអស់គ្នាត្រូវការពារមុខមាត់ របស់ក្រុមហ៊ុន។ ដូចនេះហើយ វាសំខាន់ណាស់ថា ទំនាក់ទំនងសាធារណៈរបស់យើងត្រូវគ្រប់គ្រងឲ្យបានប្រុងប្រយ័ត្ន។

អ្នកមិនមានសិទ្ធនិយាយជាតំណាងឲ្យក្រុមហ៊ុននៅទីសាធារណៈ។ លើសពីនេះទៀត អ្នកមិនត្រូវបានអនុញ្ញាតឱ្យផ្តល់យោបល់ជាសាធារណៈលើក្រុមហ៊ុន ឬបញ្ហាដែលទាក់ទងនឹងអាជីវកម្មរបស់យើងដោយគ្មានការយល់ព្រមជាមុនពីការផ្នែកទំនាក់ទំនងសាជីវកម្មឡើយ។

បម្រាមនេះអនុវត្តទៅលើ៖

- ការបញ្ចេញមតិក្នុងប្លុក ក្រុមពិភាក្សា ឬនៅក្នុងគេហទំព័របណ្តាញសង្គម។
- ការបញ្ចេញមតិនៅក្នុងសិក្ខាសាលាសាធារណៈ
- ការនិយាយតាមឧបករណ៍ផ្សាយសំលេង ឬកាសែត។

រាល់សំណើរទាំងអស់សម្រាប់ការបញ្ចេញមតិជាសាធារណៈត្រូវឲ្យអ្នកគ្រប់គ្រងរបស់ អ្នកជាអ្នកធ្វើ។

អ្នកគួរចងចាំថាក្រមនេះជាឯកសារសាធារណៈ បញ្ហាដែលកើតឡើងក្រៅពីក្រម (ដូចជា ការរំលោភបំពានជាក់លាក់ មិនមែនជាពត៌មានសាធារណៈទេហើយអ្នកមិនត្រូវ ផ្សព្វផ្សាយវាទៅក្រៅសហគ្រាស Zuellig Pharma ទេ។

**ប្រព័ន្ធផ្សព្វផ្សាយសង្គម**

Zuellig Pharma មិនមានបំណងចង់ជ្រៀតជ្រែកក្នុងសកម្មភាពបណ្តាញសង្គមរបស់អ្នកទេ។ ទោះយ៉ាងណាក៏ដោយ នៅពេលដែលសកម្មភាពបែបនេះជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការងាររបស់អ្នក ឬការអនុវត្តការងាររបស់និយោជិកផ្សេងទៀត ឬផលប្រយោជន៍អាជីវកម្ម និងកេរ្តិ៍ឈ្មោះអាជីវកម្មរបស់ក្រុមហ៊ុន នោះZuellig Pharma សូមរក្សាសិទ្ធិក្នុងការចាត់វិធានការសមស្រប ដើម្បីការពារកេរ្តិ៍ឈ្មោះរបស់ Zuellig Pharma ។

សូមជ្រាបថាគេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម ត្រូវបានត្រួតពិនិត្យកាន់តែខ្លាំងឡើង ពីសំណាក់អតិថិជនមិត្តរួមការងារអតិថិជន និងបញ្ញត្តិករដូចគ្នា។

**រក្សាពត៏មានរបស់យើងនៅក្នុងក្រុមហ៊ុន។**

**អ្នកទទួលខុសត្រូវចំពោះអ្វីគ្រប់យ៉ាងដែលអ្នកបានប្រកាស ហើយអ្វីគ្រប់យ៉ាងដែលអ្នកបានផ្សាយនឹងក្លាយជាការឆ្លុះបញ្ចាំងរបស់អ្នក និងអង្គភាពរបស់យើង។**



12

# បរិស្ថាន

## គិតអំពីអនាគតរបស់យើង

សហគ្រាស Zuellig Pharma យល់ថាវាមានការទទួលខុសត្រូវដោយសីលធម៌ក្នុងការការពារបរិស្ថាន និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិបរិស្ថាន។ វាចាំបាច់សម្រាប់យើងដែលបញ្ជាក់ការតាំងចិត្តរបស់យើងនៅក្នុងក្រុមនេះ។

យើងប្តេជ្ញាក្នុងការការពារបរិស្ថានជាផ្នែកមួយនៃការសម្រេចចិត្តរៀងរាល់ថ្ងៃរបស់យើង។ សកម្មភាពទទួលខុសត្រូវបរិស្ថានមិនត្រឹមតែសំខាន់សម្រាប់ភ្ញៀវ អតិថិជន និងបុគ្គលពាក់ព័ន្ធរបស់យើងប៉ុណ្ណោះទេ តែវាជាអ្វីដែលត្រឹមត្រូវ។ គោលដៅរបស់យើងគឺបញ្ចៀសរាល់ស្ថានភាពណាមួយដែលអាចនាំឲ្យមានភាពមិនអាចទទួលយកបាននៃបរិស្ថាន ឬគ្រោះថ្នាក់សុខភាពសម្រាប់បុគ្គលិក សាធារណ ឬបរិស្ថានជាទូទៅ។

បន្ថែមពីនេះ ច្បាប់បរិស្ថាននៅក្នុងប្រទេសផ្សេងៗអនុវត្តចំពោះប្រតិបត្តិការរបស់ យើង។ យើងទាំងអស់គ្នាទទួលខុសត្រូវសម្រាប់ការអនុលោមតាមទាំងតាមអក្សរ និងស្មារតីនៃច្បាប់ និងបទប្បញ្ញត្តិបរិស្ថានជាធរមាន រួមទាំងការប្រើប្រាស់ និងការបោះចោលកាកសំណល់ឲ្យបានត្រឹមត្រូវ រួមមាន៖

- ការគ្រប់គ្រងកាកសំណល់គ្រោះថ្នាក់ និងការសំណល់រឹង
- ការគ្រប់គ្រងសារធាតុ ពុល
- ទ្រព្យសម្បត្តិដែលខូច និងហួសកំណត់

**Q:** ខ្ញុំបានទៅមើលឃ្លាំងទំនិញមួយនៃឃ្លាំងទំនិញរបស់យើង ថ្មីៗនេះ ហើយមានបុគ្គលិកម្នាក់ប្រាប់ខ្ញុំថា យើងមិនបានបំផ្លាញចោលឱសថដែលហួសកាលកំណត់ស្របតាមច្បាប់បរិស្ថានមូលដ្ឋាននៅឡើយទេ។ តើខ្ញុំត្រូវធ្វើដូចម្តេច?

**A:** យើងទាំងអស់គ្នាត្រូវទទួលខុសត្រូវសម្រាប់ការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិបរិស្ថាន ដែលអនុវត្តចំពោះការបំផ្លាញទំនិញហួសកំណត់។ អ្នកត្រូវទាក់ទងទៅប្រធានគ្រប់គ្រងរបស់អ្នក ផ្នែកធនធានមនុស្ស ឬ មន្ត្រីប្រតិបត្តិតាម ឬអ្នកគ្រប់គ្រងជាន់ខ្ពស់របស់អ្នក។

> ការគោរពចំពោះបរិស្ថាន ដែលយើងប្រតិបត្តិជំនួញ គឺជាអាជីវកម្មល្អ។



13

# អន្តរកម្មជាមួយអ្នកផ្តល់សេវាថែទាំសុខភាព

*ស្តង់ដារសីលធម៌ខ្ពស់បំផុត ត្រូវតែអនុវត្តនៅពេលទំនាក់ទំនងជាមួយអ្នកផ្តល់សេវា ថែទាំសុខភាព* **(HCPs)**

**Q:** ខ្ញុំចង់ផ្ញើផ្កាខ្លះ ដើម្បីអបអរសាទរវេជ្ជបណ្ឌិត A សម្រាប់ការបើកគ្លីនិកថ្មីរបស់គាត់។ ទោះជាយ៉ាងណាក៏ដោយ វាត្រូវបានហាមឃាត់ដោយក្រមសីលធម៌ និងគោលការណ៍IHCP ។ តើខ្ញុំគួរប្រើលុយផ្ទាល់ខ្លួនដើម្បីបង់ថ្លៃផ្កាមែនទេ?

**A:** អត់ទេ។ អំណោយសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ HCPs ត្រូវបានហាមឃាត់ ហើយនិយោជិកZuellig Pharma មិនអាចប្រើប្រាស់មូលនិធិផ្ទាល់ខ្លួន សម្រាប់គោលបំណងណាមួយ ឬតាមរបៀបណាមួយដែលការប្រើប្រាស់មូលនិធិរបស់ក្រុមហ៊ុននឹងត្រូវបានហាមឃាត់ឡើយ។

យើងប្តេជ្ញាគោរព ការវិនិច្ឆ័យឯករាជ្យនៃHCP។ ក្នុងកាលៈទេសៈណាក៏ដោយយើងមិនគួរមានឥទ្ធិពលមិនត្រឹមត្រូវទៅលើការអនុវត្តន៍ ឬការសំរេចចិត្តរបស់HCPឡើយ។ និយោជិក និងអ្នកតំណាងមិនអាចផ្តល់នូវអ្វីដែលមានតម្លៃ រួមទាំងការទូទាត់ អំណោយ បដិសណ្ឋារកិច្ច ការឧបត្ថម្ភ ឬអត្ថប្រយោជន៍ផ្សេងទៀតដល់ HCP ដើម្បីផ្តល់ភាពមិនសមរម្យដល់ HCP ដើម្បីអនុម័ត ចេញវេជ្ជបញ្ជា ណែនាំ ផ្សព្វផ្សាយ ទិញ ផ្គត់ផ្គង់ និងគ្រប់គ្រងផលិតផលវេជ្ជសាស្ត្រណាមួយ ឬសេវាកម្ម។

រាល់ការដោះដូរតម្លៃ រួមទាំងអាហារ បដិសណ្ឋារកិច្ច ការធ្វើដំណើរ ការស្នាក់នៅ និងថ្លៃសេវាកម្ម រវាងZuellig Pharma និង HCP ត្រូវតែមានឯកសារ និងអនុលោមតាមច្បាប់ក្នុងស្រុក និងក្រមរបស់សហគ្រាស ក៏ដូចជាគោលនយោបាយរបស់Zuellig Pharma ផងដែរ។

ដូច្នេះវាមានសារៈសំខាន់ណាស់ សម្រាប់ក្រុមហ៊ុនដែលនិយោជិករបស់យើង ជាពិសេសអ្នកដែលមានអន្តរកម្មជាមួយ HCP នៅក្នុងប្រតិបត្តិការរបស់ពួកគេ អោយយល់ពីសារៈសំខាន់ នៃការធ្វើសកម្មភាពប្រកបដោយសច្ចភាពនិងភាពស្មោះត្រង់ នៅក្នុងទំនាក់ទំនងរបស់យើងជាមួយ HCP ។

រាល់ការប្រាស្រ័យទាក់ទងជាមួយ HCP ត្រូវតែអនុវត្តតាមក្រមនេះ និងអន្តរកម្មរបស់យើងជាមួយគោលនយោបាយអ្នកផ្តល់សេវាថែទាំសុខភាព (គោលនយោបាយ IHCP) ក៏ដូចជាគោលនយោបាយរបស់យើងស្តីពីការប្រឆាំងអំពើពុករលួយ និងប្រឆាំងការសូកប៉ាន់ និងអំណោយ បដិសណ្ឋារកិច្ច និងអត្ថប្រយោជន៍ផ្សេងៗទៀត។

**ចងចាំជានិច្ច៖**

- គុណប្រយោជន៍របស់អ្នកជំងឺ និងគោលបំណងវិទ្យាសាស្ត្រជាអាទិភាព
- អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ដែលអាចអនុវត្តបានទាំងអស់ បទដ្ឋាន ក្រមរបស់សហគ្រាស មូលដ្ឋានការអនុវត្ត និងដែនកំណត់ដែលអាចអនុវត្តបាន
- អំណោយ ឬសេវាកម្មផ្ទាល់ខ្លួនសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួននៃHCP

នៅពេលមានការសង្ស័យ សូមយោងទៅលើក្រមនេះ និងគោលការណ៍ IHCP ឬទាក់ទងទៅអ្នកគ្រប់គ្រង ឬមន្ត្រីផ្នែកប្រតិបត្តិតាមរបស់អ្នក។

> ផ្ញើអន្តរកម្មជាមួយ *HCPs* ក្នុងលក្ខណៈមួយដែលមានតម្លាភាព ដោយគ្មានគោលបំណង ឬទំនោរនៃការលាក់បាំង” ។

14

# ការគ្រប់គ្រងព័ត៌មានសុខភាព

**Q:** មិត្តរួមការងាររបស់អ្នកបានបង្កើត និងបង្ហោះសម្ភារៈផ្សព្វផ្សាយដែលមិនត្រូវបានអនុម័តសម្រាប់ផលិតផលវេជ្ជបញ្ជាដែលត្រូវបានចាប់ផ្តើមឆាប់ៗនៅលើគេហទំព័របណ្តាញផ្សព្វផ្សាយសង្គមផ្ទាល់ខ្លួនរបស់គាត់។ តើវាសមស្របដែររឺទេ?

**A:** ទេ ច្បាប់បទប្បញ្ញត្តិ និងក្រមសុខាភិបាលភាគច្រើនមានការរឹតត្បិត លើការលើកកម្ពស់ផលិតផល ដែលបានកំនត់ក្នុងទីសាធារណៈ។ សំភារៈផ្សព្វផ្សាយត្រូវតែប្រកាន់ខ្ជាប់នូវដំណើរការអនុម័តផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលមានមុខងារពាក់ព័ន្ធ - កិច្ចការបទបញ្ញត្តិនិងវេជ្ជសាស្ត្រ - ហើយក៏ត្រូវគោរពតាមគោលការណ៍ណែនាំនៃការទំនាក់ទំនងមុនពេលត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឬផ្សព្វផ្សាយរួមទាំងនៅលើគេហទំព័របណ្តាញផ្សព្វផ្សាយសង្គម។

## *ការពារសុខុមាលភាពនិងសុវត្ថិភាពរបស់អ្នកជំងឺ*

សុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់អ្នកជំងឺ គឺជាអាទិភាពទីមួយរបស់យើង។ តាមច្បាប់បទប្បញ្ញត្តិ និងក្រមសុខាភិបាលមូលដ្ឋាន ដែលអាចអនុវត្តបាន ព័ត៌មានទាក់ទងនឹងផលិតផល ត្រូវតែជាការពិត ហើយការទាមទារទាក់ទងនឹងផលិតផល ត្រូវតែមានភាពត្រឹមត្រូវ និងមានភស្តុតាង។ គុណភាព និងសុវត្ថិភាពនៃផលិតផលរបស់យើង មិនអាចត្រូវបានសម្របសម្រួលឡើយ។ ការរាយការណ៍ច្បាស់លាស់ អំពីការមិនពេញចិត្ត ទាក់ទងនឹងការប្រើប្រាស់ផលិតផលចែកចាយ ឬផ្សព្វផ្សាយ ដោយយើងជាពិសេស លើសុវត្ថិភាព គុណភាព និងលទ្ធផលជួយយើងឱ្យចាត់វិធានការសមស្របដើម្បីកាត់បន្ថយហានិភ័យ។

**វិទ្យាសាស្ត្រ វេជ្ជសាស្ត្រ និងសម្ភារៈផ្សព្វផ្សាយ**

យើងរក្សាស្តង់ដារខ្ពស់ នៃការលើកកម្ពស់ក្រមសីលធម៌ និងទំនាក់ទំនងវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រស្របតាមច្បាប់បទបញ្ញត្តិនិងក្រម។
ការផ្សាយពាណិជ្ជកម្ម ក៏ដូចជាទំរង់ផ្សេងៗ នៃសំភារៈទំនាក់ទំនងទាក់ទងនឹងផលិតផល ត្រូវតែជាការពិតហើយការទាមទារជាក់លាក់ ត្រូវតែមានភាពត្រឹមត្រូវនិងមានភស្តុតាង។ យើងមិនត្រូវបំភ័ន្ត ឬនិយាយការពិតហួសហេតុ ឬផ្តល់សេចក្តីថ្លែងការណ៍មិនពិត ឬបោកបញ្ឆោតអំពីផលិតផលរបស់យើង ឬអ្នកប្រកួតប្រជែង។ សំភារៈដែលត្រូវបានបង្កើតឡើង សម្រាប់ប្រើប្រាស់នៅក្នុងទីផ្សារ ត្រូវតែត្រូវបានពិនិត្យ និងអនុម័តតាមតម្រូវការ និងគោលការណ៍ដែលអាចអនុវត្តបានមុនពេលប្រើប្រាស់។ និយោជិកត្រូវអនុវត្តតាមដំណើរការដែលបានបង្កើតឡើងដើម្បីទទួលបានការអនុម័ត ច្បាប់និងបទប្បញ្ញត្តិមុនពេលអនុវត្តសកម្មភាពទីផ្សារ។

> ”
> កុំប្រើព័ត៌មានផលិតផល ដែលមិនមានការអនុញ្ញាត ឬបង្ហាញព័ត៌មានមិនពិតជាមួយនឹងពាក្យបណ្តឹងមិនពិត” ។



**របាយការណ៍ព្រឹត្តិការណ៍មិនល្អ**

ចូរចងចាំថា របាយការណ៍ព្រឹត្តិការណ៍មិនល្អអាចមានផលវិបាកគួរឱ្យកត់សម្គាល់ ដែលត្រូវយកចិត្តទុកដាក់ និងចាត់វិធានការភ្លាមៗ។ និយោជិករបស់យើងទាំងអស់ ត្រូវរាយការណ៍ទៅមុខងារដែលទាក់ទងនឹងការគ្រប់គ្រងឱសថសាស្ត្រ រួមទាំងមិនមានកំណត់ចំពោះកិច្ចការបទបញ្ញត្តិ ការធានាគុណភាពជាដើម។

15

# ការប្រកួតប្រជែងដោយស្មើភាព

*ការប្រកួតប្រជែងដោយស្មោះត្រង់នៅក្នុងទីផ្សារ*

**Q:** នៅឯសិក្ខាសាលាឧស្សាហកម្មនាពេលថ្មីៗនេះ ខ្ញុំបានជួបអតីតអ្នកធ្វើការជាមួយ ដែលកំពុងបំពេញការងារឲ្យគូប្រកួតប្រជែង។ គាត់បានចាប់ផ្តើម និយាយអំពីវិធីដែលយើងអាចកាត់បន្ថយ ការបញ្ចុះតម្លៃ ការទូទាត់ត្រឹមត្រូវ។ តើខ្ញុំគួរធ្វើដូចម្តេច?

**A:** អ្នកត្រូវប្រាប់ អតីតអ្នកធ្វើការជាមួយអោយបញ្ឈប់ការពិភាក្សាអំពីប្រធានបទនេះ ដោយហេតុថា ការសន្ទនាប្រភេទនេះ អាចបង្ហាញនូវបំណង ដាក់កំហិតការប្រកួតប្រជែង និងបំពានច្បាប់ស្តីពីការប្រកួតប្រជែងផងដែរ។ អ្នកក៏គួរតែ ប្រាប់អ្នកគ្រប់គ្រងរបស់អ្នក អំពីការសន្ទនារបស់អ្នកភ្លាមៗ។

វាមានផលវិបាកធ្ងន់ធ្ងរចំពោះការបំពានច្បាប់ស្តីពីការប្រកួតប្រជែង ក៏ដូចជាការបំផ្លាញ កេរ្តិ៍ឈ្មោះរបស់យើង នៅពេលដែលយើងប្រកួតប្រជែងអាជីវកម្មមិនស្មោះត្រង់។ វាមានការចាំបាច់ដែលម្នាក់ៗយល់អំពីឥរិយាបទនៅពេលធ្វើអាជីវកម្មសហគ្រាស Zuellig Pharma។

ច្បាប់ស្តីពីការប្រកួតប្រជែងហាមការធ្វើអាជីវកម្ម ដែលជ្រៀតជ្រែកទៅនឹងការប្រកួតប្រជែងដោយបើកចំហ និងដោយសេរី និងអាចពាក់ព័ន្ធអ្នកប្រកួតប្រជែង អ្នកផ្គត់ផ្គង់ អ្នកចែកចាយ ឬអតិថិជន។ ក្រុមហ៊ុនប្តេជ្ញាគោរពតាមទាំងផ្នែកស្មារតី និងភាសានៃច្បាប់ទាំងនេះ។ យើងតែងតែប្រកួតប្រជែងដោយស្របច្បាប់នៅក្នុងទីផ្សារ និងការប្តេជ្ញាចិត្តរបស់យើងចំពោះសិទ្ធិរបស់ដៃគូប្រកួតប្រជែងរបស់យើង អតិថិជន និងសហគមន៍។

ច្បាប់ទាំងនេះមានភាពស្មុគស្មាញ និងផ្សេងគ្នាគួរឲ្យកត់សម្គាល់ពីប្រទេសមួយ ទៅប្រទេសមួយទៀត។ ប្រសិនបើអ្នកមានសំណួរ អ្នកត្រូវសួរប្រធានគ្រប់គ្រង រឺផ្នែកច្បាប់របស់អ្នកជានិច្ច។

**ចូរចងចាំជានិច្ចថា៖**

- មិនត្រូវពិភាក្សា ជាមួយដៃគូប្រកួតប្រជែងរបស់យើងអំពីលក្ខខណ្ឌជំនួញដូចជាតម្លៃ ការចុះតម្លៃ ការទូទាត់ ឬការប្រមូលប្រាក់ឡើយ។
- មិនត្រូវពិភាក្សា ជាមួយអតិថិជន អំពីតម្លៃ ឬការបញ្ចុះតម្លៃរបស់យើងលើផលិតផលរបស់អតិថិជនផ្សេងទៀត។
- មិនត្រូវបែងចែកទីផ្សារ ដែនដី ឬអតិថិជនជាមួយគូប្រកួតឡើយ។
- មិនត្រូវកម្រិតអតិថិជនពីការទិញផលិតផលមួយលើលក្ខខណ្ឌដែលគេត្រូវតែទិញផលិតផលមួយផ្សេងទៀតនោះទេ។ អតិថិជនមានសិទ្ធិទិញដាច់ដោយឡែកពីគ្នា។
- មិនត្រូវប្រមូលផ្តុំព័ត៌មាន ដៃគូប្រកួតប្រជែងក្នុងទម្រង់អសីលធម៌ ឬមិនស្របច្បាប់។

> យើងត្រូវប្រកួតប្រជែងលើគុណភាពសេវានិងមិនត្រូវពាក់ព័ន្ធទៅក្នុងទម្រង់នៅការប្រកួតប្រជែងមិនស្មោះត្រង់ណាមួយឡើយ។



16

# ភ្ញៀវ អតិថិជន និងបុគ្គលមានទំនាក់ទំនងសំខាន់ផ្សេងទៀត

*ត្រូវការពារទំនាក់ទំនង ទាំងនេះ ពីព្រោះពួកគេគឺជាគន្លឹះនៃការជោគជ័យរបស់យើង*

**Q:** ប្រធានគ្រប់គ្រងផលិតផលនៃភ្ញៀវម្នាក់បានសួរខ្ញុំអំពីលក្ខខណ្ឌចែកចាយរបស់យើងជាមួយពួកគេ ប៉ុន្តែគាត់មិនមែនជាសមាជិក "មានសិទ្ធិ" ចុះកិច្ចព្រមព្រៀងចែកចាយនោះទេ។ តើខ្ញុំគួរប្រាប់គាត់អំពីលក្ខខណ្ឌនេះដែរឬទេ? ត់អំពីលក�ខណ�េនះែដរឬេទ?

**A:** មិនអាចប្រាប់បានទេ ពីព្រោះព័ត៌មាននេះមិនអាច ចែករំលែកជាមួយប្រធានគ្រប់គ្រងផលិតផលទេ។ ព័ត៌មានសម្ងាត់ត្រូវបានការពារ និងអាចត្រូវបានចែករំលែក ក្នុងជាមួយអ្នកដែលមានតម្រូវការដឹង និងអនុលោមតាម លក្ខខណ្ឌនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលអាចអនុវត្តបាន។

វាមានសារៈសំខាន់ដែលនិយោជិតម្នាក់យល់ដឹងអំពីភាពចាំបាច់នៃការធ្វើសកម្មភាពត្រឹមត្រូវនៅក្នុងទំនាក់ទំនងរបស់យើងជាមួយភ្ញៀវ អតិថិជន និងអ្នកពាក់ព័ន្ធផ្សេងទៀត។

ប្រសិនបើការងាររបស់អ្នកតម្រូវឲ្យអ្នកទំនាក់ទំនងជាមួយអតិថិជនក្រុមហ៊ុនណាម្នាក់ (ឬអតិថិជនមានសក្តានុពល) ភ្ញៀវ ឬអ្នកពាក់ព័ន្ធផ្សេងទៀត វាសំខាន់ណាស់សម្រាប់អ្នកដែលចងចាំថាអ្នកតំណាងឲ្យក្រុមហ៊ុន និងតម្លៃរបស់ក្រុមហ៊ុន។ សកម្មភាពក្នុងទម្រង់ដែលតែងតែបង្កើតតម្លៃ និងជួយបង្កើតទំនាក់ទំនងគឺផ្អែកលើការជឿទុកចិត្ត។ យើងបានផ្តល់សេវាថែទាសុខភាពអស់រយៈពេលជាច្រើនឆ្នាំ និង បានបង្កើតសុច្ឆន្ទៈជាយូរមកហើយ។ នេះគឺជាទ្រព្យសម្បត្តិដ៏សំខាន់មួយក្នុងចំណោមទ្រព្យសម្បត្តិមានតម្លៃផ្សេងទៀត ហើយនិយោជិតរបស់ក្រុមហ៊ុនត្រូវការពារ និងពង្រឹងកេរ្តិ៍ឈ្មោះរបស់យើង។

ភ្ញៀវ អតិថិជន និងអ្នកពាក់ព័ន្ធផ្សេងទៀត គឺសំខាន់ណាស់ចំពោះអនាគតរបស់យើង។ ដើម្បីបង្កើតបរិយាកាសដែលពួកគេមានការលើកទឹកចិត្តឲ្យធ្វើការជាមួយក្រុមហ៊ុន ពួកគេត្រូវតែមានទំនុកចិត្តដែលគេនឹងត្រូវប្រព្រឹត្តស្របច្បាប់ និងក្នុងទម្រង់មានសីលធម៌។

**ចូរចងចាំជានិច្ចថា៖**

- ប្រព្រឹត្តចំពោះភាគីទាំងអស់ដោយស្មើភាព និងដោយគោរព និងព្យាយាមបង្កើតការជឿទុកចិត្តសម្រាប់ទំនាក់ទំនងទាំងអស់ជានិច្ច។
- មិនត្រូវព្យាយាមបង្ខំភ្ញៀវ អតិថិជន ឬបុគ្គលពាក់ព័ន្ធផ្សេងតាមវិធីណាមួយដោយចេតនាពុករលួយ។
- ការពារព័ត៌មានសម្ងាត់របស់ភ្ញៀវ អតិថិជន និងបុគ្គលពាក់ព័ន្ធផ្សេងទៀត។



> ត្រូវអនុវត្តក្នុងទម្រង់ដែលបង្កើតទំនាក់ទំនងដោយផ្អែកលើការជឿជាក់ និងសេចក្តីសុចរិតជានិច្ច។

17

# ការការពារព័ត៌មានសម្ងាត់

*ព័ត៌មានគឺជាអត្ថប្រយោជន៍ប្រកួតប្រជែងរបស់យើង*

ព័ត៌មានសម្ងាត់ គឺមានសារសំខាន់ចំពោះអាជីវកម្មរបស់យើង និងទំនាក់ទំនងជាមួយតតិយជន។
ក្រមនេះផ្តល់ការណែនាំស្តីពីអ្វីទៅជាព័ត៌មានសម្ងាត់ និង វិធីការពារ។

**Q:** ប្រធានគ្រប់គ្រងគណនេយ្យរបស់យើង សម្រាប់ភ្ញៀវ"ក" បានសួរខ្ញុំអំពីតម្លៃសម្រាប់ភ្ញៀវ "ខ" ។ តើខ្ញុំអាចផ្តល់ព័ត៌មានដល់គាត់បានឬទេ?

**A:** មិនបានទេ។ ព័ត៌មាននេះជាព័ត៌មានសម្ងាត់របស់ភ្ញៀវ "ខ" ហើយដែលត្រូវបានការពារ។

**តើអ្វីជាព័ត៌មានសម្ងាត់?**

ព័ត៌មានសម្ងាត់គឺជាព័ត៌មានអំពីសហគ្រាស Zuellig Pharma ដែលមិនមែនសម្រាប់ការដឹងជាសាធារណៈ ឬជាការ អះអាងត្រឹមត្រូវ។ ជាទូទៅ ព័ត៌មានសម្ងាត់មានតម្លៃពាណិជ្ជកម្មសម្រាប់អាជីវកម្មរបស់ក្រុម ហ៊ុន និងផ្តល់ផលប្រយោជន៍ដល់ដៃគូប្រកួតប្រជែង។

**ឧទាហរណ៍ខ្លះៗអំពីព័ត៌មានសម្ងាត់៖**

- យុទ្ធសាស្ត្រ
- គម្រោងថវិកា
- ដំណើរការអាជីវកម្ម និងប្រព័ន្ធព័ត៌មាន
- កម្មសិទ្ធិបញ្ញា
- ជំនួញ និង ការចុះថ្លៃ
- គោលនយោបាយ និង នីតិវិធី
- កម្រិតចែកចាយ
- អាចកំបាំងជំនួញ និងសមត្ថភាពបំពេញសេវា
- ទិន្នន័យលក់
- លក្ខខណ្ឌគណទាន វិធីសាស្ត្រទូទាត់ និងការប្រមូលប្រាក់
- តម្លៃ និង ព័ត៌មានថ្លៃ
- ព័ត៌មានទីផ្សារ
- លក្ខខណ្ឌកិច្ចសន្យា និងព័ត៌មានពាណិជ្ជកម្មផ្សេងទៀត
- ប្រាក់ខែបុគ្គលិក និងការផ្តល់សំណង



បុគ្គលិកទាំងអស់ត្រូវទទួលខុសត្រូវចំពោះការការពារត្រឹមត្រូវត្រូវបានអនុវត្តដើម្បីការពារការបង្ហាញ ឬបាត់ភាពសម្ងាត់នៃព័ត៌មានដោយគ្មានការអនុញ្ញាត។

យើងត្រូវការពារព័ត៌មានសម្ងាត់ដែលយើងទទួលពីតតិយជនតាមវិធី ដូចគ្នាដែលយើងការពារព័ត៌មានរបស់យើងដែរ និងមិនមែនសម្រាប់ផ្សព្វផ្សាយទូទៅទេ។

សូមទាក់ទងទៅ ប្រធានគ្រប់គ្រងរបស់អ្នក ពាក់ព័ន្ធនឹងការបំពានព័ត៌មានសម្ងាត់ណាមួយ ឬប្រសិនបើអ្នក មានសំណួរអំពីការដោះស្រាយបញ្ហាព័ត៌មានសម្ងាត់។

**ចូរចងចាំជានិច្ចថា៖**

- ព័ត៌មា សម្ងាត់ត្រូវបង្ហាញសម្រាប់តែបុគ្គលិកដែលត្រូវការដឹងព័ត៌មាននោះ
- មិនត្រូវលើកទឹកចិត្តបុគ្គលិករបស់គូរប្រជែង អតិថិជន ឬ អ្នកផ្គត់ផ្គង់ឲ្យបង្ហាញព័ត៌មានសម្ងាត់
- ប្រសិនបើអ្នកជួលអតីតបុគ្គលិករបស់គូប្រកួតប្រជែង អតិថិជន អ្នកផ្គត់ផ្គង់ ឬធ្វើការជាមួយបុគ្គលដែលធ្វើការឲ្យភាគីមួយក្នុងចំណោមនេះ មិនត្រូវសួរបុគ្គលនោះឲ្យបង្ហាញព័ត៌មានសម្ងាត់ដែលមិនសមស្របឡើយ
- មិនត្រូវព្យាយាមទាញយកព័ត៌មានសម្ងាត់របស់អ្នកដទៃ

> ការការពារព័ត៌មានរបស់តតិយជនគឺសំខាន់ដូចការពារព័ត៌មានសហគ្រាស *Zuelling Pharma* ដែរ។

# 18

# ព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន

*ការរក្សានូវការសន្យារបស់យើង គឺភាពឯកជននៃបុគ្គលម្នាក់ៗ*

យើងមានការទទួលខុសត្រូវច្បាស់លាស់ក្នុងការការពារ និងរក្សាទុកព័ត៌មានសម្ងាត់ផ្ទាល់ខ្លួនដែលបានប្រមូលពីអ្នកជំងឺ មុខវិជ្ជាការសាកល្បងផ្នែកវិជ្ជសាស្ត្រ វិជ្ជាជីវៈថែទាំសុខភាព HCP អតិថិជន មន្ទីរព្យាបាលពិសោធ និងបុគ្គលិក។ ស្តង់ដារខ្ពស់បំផុតនៃសេចក្តីថ្លៃថ្នូរត្រូវតែអនុវត្ត នៅពេលដោះស្រាយលើព័ត៌មានបុគ្គល។

យើង និងដៃគូជំនួញរបស់យើង ត្រូវទទួលខុសត្រូវក្នុងការការពារព័ត៌មានបុគ្គលទាំងអស់គ្នា និងដើម្បីដំណើរការព័ត៌មានទាំងនោះតែក្នុងដែនកំណត់ដោយច្បាប់ និងគោលនយោបាយ និងនីតិវិធី ZP ប៉ុណ្ណោះ។

**Q:** តើខ្ញុំគួធ្វើយ៉ាងដូចម្តេច ប្រសិនបើខ្ញុំធ្វើឲ្យបាត់ USB របស់ ខ្ញុំដែលមានផ្ទុកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជំងឺដោយចៃដន្យ?

**A:** ត្រូវរាយការណ៍ហេតុការនេះភ្លាមៗទៅមន្ត្រីទិន្នន័យឯកជននៅក្នុងប្រទេសរបស់អ្នក និងអ្នកគ្រប់គ្រងផ្ទាល់របស់អ្នក។

ការរក្សាទុកព័ត៌មានផ្ទាល់ខ្លួន នៅឧបករណ៍ផ្ទុកត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតសម្រាប់តម្រូវការអាជីវកម្ម និងព័ត៌មាន ផ្ទាល់ខ្លួនត្រូវដាក់កូដសម្ងាត់ការពារ។

**តើព័ត៌មានផ្ទាល់ខ្លួនជាអ្វី?**

ព័ត៌មានផ្ទាល់ខ្លួន (ពេលខ្លះសំដៅដល់ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គល) ជាព័ត៌មានដែលទាក់ទងអំពី ឬអាចទាក់ទងទៅនឹងការកំណត់អត្តសញ្ញាណរបស់បុគ្គលណាម្នាក់។ ឧទាហរណ៍ខ្លះៗនៃព័ត៌មានផ្ទាល់ខ្លួន៖

- ឈ្មោះ
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- លេខទូរស័ព្ទ
- ផ្ទះ ឬអាស័យដ្ឋាន អ៊ីម៉ែល
- លេខអត្តសញ្ញាណប័ណ្ណជាតិ ឬលេខលិខិតឆ្លងដែន
- ប្រវត្តិព្យាបាល
- ប្រវត្តិវេជ្ជបញ្ជា
- កំណត់បង្ហាញគ្រូពេទ្យ
- ព័ត៌មានហិរញ្ញវត្ថុ
- ប្រវត្តិការទិញ
- ព័ត៌មានលម្អិតអំពីគណនីធនាគារ
- ស្ថានភាពគ្រួសារ
- ពូជសាសន៍ / ជាតិកំណើត
- ជំនឿសាសនា
- ការផ្តន្ទាទោស ឬឧក្រិដ្ឋកម្ម

លេខអត្តសញ្ញាណប័ណ្ណជាតិ ឬលេខលិខិតឆ្លងដែន យើងត្រូវប្រាកដថា យើងអនុលោមតាមច្បាប់មូលដ្ឋាន នៅពេលដែលយើងប្រមូល ស្តុក ប្រើប្រាស់ បង្ហាញ និងបំផ្លាញព័ត៌មានផ្ទាល់ខ្លួន។

**ចូរចងចាំជានិច្ចថា៖**

- រក្សាទុកព័ត៌មានផ្ទាល់ខ្លួនសម្ងាត់បំផុត និងប្រើប្រាស់ ឬបង្ហាញវាស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងនៅពេលចាំបាច់ ក្រោយពេលទទួលបានសេចក្តីជូនដំណឹង ឬទទួលបានការយល់ព្រមពីបុគ្គលនោះ។
- ចាត់វិធានការព្រមានដើម្បីការពារព័ត៌មានផ្ទាល់ខ្លួន។
- ការថតចម្លងព័ត៌មានផ្ទាល់ខ្លួន (ឯកសារ ឬសូហ្វកូពី) ឬផ្ទេរ រក្សាទុកព័ត៌មានផ្ទាល់ខ្លួននៅលើឧបករណ៍ផ្ទុក ត្រូវបានហាមឃាត់ លើកលែងតែមានការយល់ព្រមតម្រូវការអាជីវកម្ម ហើយព័ត៌មានផ្ទាល់ខ្លួនត្រូវដាក់លេខកូដការពារ ឬចងកូដ។
- បំផ្លាញកំណត់ត្រាដែលផ្ទុកព័ត៌មានផ្ទាល់ខ្លួនឲ្យបានត្រឹមត្រូវ។
- ប្រមូលព័ត៌មានផ្ទាល់ខ្លួនតែសម្រាប់គោលបំណងអាជីវកម្មស្របច្បាប់ និងរក្សាវាទុកតាមដែលចាំបាច់ប៉ុណ្ណោះ
- ព័ត៌មានផ្ទាល់ខ្លួនមិនត្រូវបង្ហាញទៅតតិយជនឡើយ លើកលែងតែយើងទទួលបានការអនុញ្ញាតពីបុគ្គលនោះ ឬមានហេតុផលតាមច្បាប់តម្រូវឲ្យធ្វើដូច្នេះ។
- ចែករំលែកព័ត៌មានផ្ទាល់ខ្លួនតែជាមួយបុគ្គលដែលមានតម្រូវការស្របច្បាប់ ហើយការពារវាយ៉ាងល្អ។

> ត្រូវការពារព័ត៌មានផ្ទាល់ខ្លួនឲ្យដូចជាការប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនត្រូវបានប្រើ។

# 19

**Q:** ខ្ញុំដឹងថា ភ្ញៀវម្នាក់ក្នុងចំណោមភ្ញៀវរបស់យើងគឺស្ថិតនៅក្នុងដំណាក់កាល ចុងក្រោយនៃមន្ទីរពេទ្យសាកល្បង ក្នុងការ រៀបចំដំណើរការផលិតផលថ្មី។ តើខ្ញុំអាចឲ្យភរិយារបស់ខ្ញុំ ទិញភាគហ៊ុនខ្លះបានឬទេ?

**A:** មិនអាចទេ។ ប្រសិនបើអ្នកដឹងព័ត៌មានខាងក្នុងអំពីភ្ញៀវ អ្នកមិនអាចប្រើប្រាស់ព័ត៌មាននេះ ដើម្បីទទួលចំណេញផ្ទាល់ខ្លួន ឬប្រាប់ព័ត៌មាននេះដល់អ្នកផ្សេង ដូចជាសាច់ញាតិ ឬមិត្តភ័ក្រ ដើម្បីទទួលការចំណេញឡើយ ក្នុងនាមជាពួកគេ ឬក្នុងនាមអ្នកនោះឡើយ។




**អ្នកមិនអាចប្រើប្រាស់ព័ត៌មានផ្ទៃក្នុង ក្នុងការជួញដូរមូលបត្រសម្រាប់អត្ថប្រយោជន៍ផ្ទាល់ខ្លួនឡើយ។**

# ការជួញដូរអំពីព័ត៌មានខាងក្នុង

*ការជួញដូរលើព័ត៌មានខាងក្នុងគឺជាអំពើខុសច្បាប់ និងអនុវត្តចំពោះបុគ្គលិករបស់សហគ្រាស **Zuellig Pharma** ទាំងអស់*

វាមានភាពចាំបាច់ណាស់ សម្រាប់ពួកយើងក្នុងការផ្តល់ការណែនាំអំពីការជួញដូរលើព័ត៌មានខាងក្នុងក្រមនេះ ពីព្រោះវាអាចបង្កឲ្យអ្នកមានបណ្តឹងរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយបំផ្លាញមុខមាត់របស់សហគ្រាស Zuellig Pharma ឬទំនាក់ទំនងរបស់ខ្លួនជាមួយគតិយជន។

ក្នុងអំឡុងពេលធ្វើសកម្មភាពជាមួយភ្ញៀវ អតិថិជន និងភាគីតតិយជន អ្នកអាចទទួលព័ត៌មានមិនសាធារណៈ ឬ ព័ត៌មាន “ខាងក្នុង ដែលផ្តល់ប្រយោជន៍ពាណិជ្ជកម្ម។ ចូរចាំថាច្បាប់ស្តីពីសន្តិសុខអនុវត្តចំពោះបុគ្គលគ្រប់រូប មិនមែនចំពោះតែបុគ្គលិកនៃក្រុមហ៊ុនសាធារណៈទេ។ ប្រសិនបើអ្នកកាន់កាប់ព័ត៌មានខាងក្នុង អ្នកមិនអាចបង្ហាញវាដោយទិញ ឬលក់ភាគហ៊ុនផ្ទាល់ខ្លួនរបស់អ្នក ឬអាចផ្តល់វាទៅបុគ្គលផ្សេងដើម្បីឲ្យគេទទួលបានប្រយោជន៍សម្រាប់ខ្លួនតែ ឬសម្រាប់ជំនួសអ្នកទេ។

**ព័ត៌មានខាងក្នុង (ឯកសារមិនសាធារណៈ)**

ព័ត៌មានអំពីក្រុមហ៊ុនដែលមិនអាចដឹងជាទូទៅ ហើយដែលអ្នកវិនិយោគគិតថាវាសំខាន់ក្នុងការធ្វើសេចក្តីសម្រេចទិញ លក់ ឬកាន់កាប់ក្រុមហ៊ុនមូលបត្រ។ វាអាចរួមទាំងព័ត៌មានដែលខ្លះដូចជានឹងកើតមាន ឬគ្រាន់តែថាវាអាចនឹងកើតមាន។

**តើអ្វីខ្លះត្រូវគិតថាជាព័ត៌មានខាងក្នុង?**

- ការប៉ាន់ប្រមាណអំពីចំណូល ឬខាតបង់នាពេលអនាគត។
- ការប្រមើលអត្រាវិកលូតលាស
- ការចរចា ពិភាក្សា និងការព្រមព្រៀងទាក់ទងនឹងការទិញយកធំៗ បញ្ហា ឬទំនាក់ទំនងយុទ្ធសាស្ត្រ។
- ការផ្លាស់ប្តូរថ្នាក់ដឹកនាំ
- ផលិតផលថ្មីចាំបាច់ និងការបង្ហាញផលិតផល
- លទ្ធផលការសាកល្បងផ្នែកវិជ្ជសាស្ត្រ
- ការចំណេញ ឬខាតនៃភ្ញៀវ ឬអតិថិជនចម្បង
- ព័ត៌មានទាក់ទងនឹងការផ្តល់ឲ្យ ឬសកម្មភាពហិរញ្ញវត្ថុផ្សេងៗ។

**តើមានអ្វីកើតមាន ប្រសិនបើខ្ញុំជួញដូរមូលបត្រផ្អែកតាមព័ត៌មានខាងក្នុង?**

ការជួញដូរផ្អែកតាម ព័ត៌មានខាងក្នុង ឬការផ្តល់ព័ត៌មានខាងក្នុងទៅនរណាម្នាក់ផ្សេងទៀត ដែលជួញដូរ (បើទោះបីអ្នកមិនទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុក្តី គឺជាបទល្មើស និងអាចឈានដល់ការពិន័យ និង/ឬការដាក់ពន្ធនាគារ។ វិធាន ការជួញដូរខាងក្នុងត្រូវអនុវត្តយ៉ាងតឹងរឹង។ អ្នកក៏អាចត្រូវទទួលរងទណ្ឌកម្មវិន័យដោយក្រុមហ៊ុនដែលរួមមានការបញ្ចប់កិច្ចសន្យាការងារ។

# 20

# បទប្បញ្ញត្តិពាណិជ្ជកម្មអន្តរជាតិ

## គោរពតាមបទប្បញ្ញត្តិពាណិជ្ជកម្មអន្តរជាតិ ដែលអាចអនុវត្តបាននិងច្បាប់ត្រួតពិនិត្យការនាំចេញ

ក្នុងការធ្វើអាជីវកម្ម បទប្បញ្ញត្តិពាណិជ្ជកម្មអន្តរជាតិ ឬការរឹតបន្តឹង អាចត្រូវបានអនុវត្តចំពោះទំនាក់ទំនងអាជីវកម្មរបស់យើង រួមទាំងចំពោះការដាក់ទណ្ឌកម្ម ការរំលោភបំពាន និងការមិនរាប់បញ្ចូលផ្សេងៗ។ ដូច្នេះZuellig Pharma ប្តេជ្ញាគោរពតាមរាល់បទប្បញ្ញត្តិពាណិជ្ជកម្មអន្តរជាតិ ដែលអាចអនុវត្តបាន និងការរឹតត្បិតលើការធ្វើអាជីវកម្ម ជាមួយមនុស្សអង្គភាព ឬប្រទេសដែលរងការដាក់ទណ្ឌកម្ម ឬត្រូវបានចុះក្នុងបញ្ជីទណ្ឌកម្មជាតិឬអន្តរជាតិ។

យើងត្រូវតែធានាថា និយោជិករបស់យើង និងបុគ្គល ឬអង្គភាពដែលធ្វើសកម្មភាពក្នុងនាមយើង ពិនិត្យមុនពេលបង្កើតទំនាក់ទំនងអាជីវកម្មណាមួយ ដើម្បីចៀសវាងការចូលធ្វើអាជីវកម្មជាមួយ ឬពាក់ព័ន្ធនឹងបុគ្គលអង្គភាព ឬប្រទេសនានា។

នៅពេលមានការសង្ស័យ ថាតើបទប្បញ្ញត្តិពាណិជ្ជកម្មអន្តរជាតិ អនុវត្តចំពោះអាជីវកម្មរបស់អ្នក សូមពិគ្រោះជាមួយអ្នកគ្រប់គ្រងរបស់អ្នកនិងផ្នែកច្បាប់។

**Q:** ហេតុអ្វីយើងចាំបាច់ ត្រូវគោរពតាមការដាក់ទណ្ឌកម្មអន្តរជាតិ និងការដាក់ទណ្ឌកម្ម?

**A:** ការចែករំលែក ឬដឹកជញ្ជូនទំនិញដែលត្រួតត្រាជាមួយមនុស្ស ឬក្រុមហ៊ុនមកពីប្រទេសជាក់លាក់មួយ អាចតម្រូវឱ្យមានការអនុញ្ញាតពិសេស ឬអាចត្រូវបានហាមឃាត់ជាដាច់ខាត ហើយការដឹកជញ្ជូនទំនិញទៅកាន់ប្រទេសមួយចំនួនអាចខុសច្បាប់។

> ចូរចងចាំជានិច្ច ថាត្រូវពិនិត្យមើលបទបញ្ជាអន្តរជាតិ មុនពេលធ្វើអាជីវកម្ម ។



21

# ការថែរក្សាទ្រព្យសម្បត្តិ & សន្ទិធិ

*ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងសន្ទិធិរូបវន្តនៅក្រោមការថែទាំរបស់យើង "គឺ" ជាអាជីវកម្មរបស់យើង*

ទ្រព្យសម្បត្តិ និងសន្ទិធិរបស់ក្រុមហ៊ុនត្រូវបានការពារកុំឲ្យបាត់បង់។ក្រមនេះលើកឡើងនូវអ្វីដែលអ្នកត្រូវធ្វើដើម្បីការពារទ្រព្យទាំងនោះ។

ការការពារទ្រព្យសម្បត្តិ និងសន្ទិធិរបស់ក្រុមហ៊ុនក្រោមការថែទាំរបស់យើងគឺជាការទទួលខុសត្រូវចម្បងរបស់បុគ្គលិក ភ្នាក់ងារ និងអ្នកម៉ៅការគ្រប់គ្នា។

បុគ្គលិកម្នាក់ៗត្រូវទទួលខុសត្រូវ សម្រាប់ការប្រើប្រាស់ត្រឹមត្រូវ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ទាំងទ្រព្យរូបិយ និងអរូបិយ ហើយត្រូវប្រើទ្រព្យទាំងនោះ តែសម្រាប់គោលបំណងអាជីវកម្មស្របច្បាប់ប៉ុណ្ណោះ។ ទ្រព្យសម្បត្តិ និងសន្ទិធិរូបិយរួមមាន តែមិនកំណត់ត្រឹមតែមជ្ឈមណ្ឌលចែកចាយ របស់យើង សាខា ឱសថស្ថាន និងស្តុកទាក់ទងនឹងការថែទាំសុខភាព សម្ភារៈ ប្រព័ន្ធHardware ។ល។ ទ្រព្យសម្បត្តិអរូបិយរួមមាន តែមិនកំណត់ត្រឹមតែ Software គាំទ្រប្រព័ន្ធគ្រប់គ្រងឃ្លាំង ប្រព័ន្ធបំពេញបញ្ជា សារអេឡិចត្រូនិកអាជីវកម្ម គោលនយោបាយ និងនីតិវិធី។ល។

បុគ្គលិកម្នាក់ៗត្រូវការពារទ្រព្យសម្បត្តិក្រុមហ៊ុន ក៏ដូចជាសន្ទិធិកុំឲ្យបាត់បង់ ខូចខាត ខុស ឬត្រូវលួច។ ការកែប្រែ ការបំផ្លាញ ការប្រើប្រាស់ ការបញ្ចេញ ឬចែក

ចាយទ្រព្យសម្បត្តិ និងសន្ទិធិរបស់ក្រុមហ៊ុនដោយគ្មានការអនុញ្ញាតគឺបំពាននឹងក្រមនេះ។

**ការរំពឹងរបស់យើងគឺថា៖**

- អ្នកនឹងអនុលោមតាមកម្រិតរូបវន្ត និងការចូលប្រព័ន្ធគ្រប់គ្រងដែលត្រូវបានផ្តល់ឲ្យអ្នក។
- អ្នកនឹងអនុវត្តការថែទាំទ្រព្យសម្បត្តិ ឬសន្ទិធិក្រុមហ៊ុន និងប្រើប្រាស់វាដោយការទទួលខុសត្រូវ។
- អ្នកនឹងចាត់វិធានការណ៍ប្រុងប្រយ័ត្នដើម្បីការងារទ្រព្យសម្បត្តិ ឬសន្ទិធិរបស់ក្រុមហ៊ុនពីការលួច ឬខូចខាត។
- អ្នកមិនត្រូវប្រើប្រាស់ ឬថតចម្លងឯកសារផ្លូវការក្រុមហ៊ុនដោយគ្មានការអនុញ្ញាត ក្រៅពីសម្រាប់គោលបំណងដែលបង្កើតឡើងប៉ុណ្ណោះ។
- អ្នកមិនត្រូវធ្វើ ឬប្រើប្រាស់ខុសច្បាប់ ឬថតចម្លងដោយគ្មានការអនុញ្ញាតនូវ Software ណាមួយឡើយ។
- អ្នកនឹងត្រូវប្រើប្រាស់ឧបករណ៍ទំនាក់ទំនងអេឡិចត្រូនិកទាំងអស់ រួមទាំងអីម៉ែល ក្រោមទម្រង់ស្របច្បាប់ មានសីលធម៌ និងសមស្រប។

**Q:** ក្នុងអំឡុងពេលនៃទស្សនកិច្ចនៅឃ្លាំងរបស់យើង បុគ្គលិកភ្ញៀវម្នាក់បានជក់បារី។ តើខ្ញុំអាចដោះស្រាយបញ្ហា នេះដូចម្តេច?

**A:** ការជក់បារីមិនត្រូវបានអនុញ្ញាតទេ នៅក្នុងឃ្លាំងទំនិញរបស់យើង។ អ្នកត្រូវស្នើដោយគួរសមទៅបុគ្គលិកភ្ញៀវឲ្យបោះបារីចោល ហើយពន្យល់ប្រាប់ថាយើងមានគោលនយោបាយហាមមិនឲ្យជក់បារី នៅក្នុងឃ្លាំងទំនិញដើម្បីការពារទ្រព្យសម្បត្តិ សន្ទិធិ និងសុខភាពរបស់បុគ្គលិក។

> ទ្រព្យសម្បត្តិ និងសន្ទិធិរបស់ក្រុមហ៊ុន ត្រូវបានប្រើប្រាស់ដើម្បីអាជីវកម្មក្រុមហ៊ុនប៉ុណ្ណោះមិនមែនសម្រាប់ផ្ទាល់ខ្លួនអ្នកឬគ្រួសារឡើយ។

22

# កំណត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ

*ភាពត្រឹមត្រូវ និងទៀងត្រង់នៃកំណត់ត្រាក្រុមហ៊ុនរបស់យើងគឺជាការសំខាន់*

សហគ្រាស Zuellig Pharma ត្រូវមានរបាយការណ៍ និងកំណត់ត្រាហិរញ្ញវត្ថុដើម្បីថ្នាក់គ្រប់គ្រងធ្វើការជូនដំណឹងសេចក្តីសម្រេច និងដើម្បីបំពេញតាមលក្ខខណ្ឌផ្សព្វផ្សាយ និងរាយការណ៍ដល់ម្ចាស់ភាគហ៊ុនពិតប្រាកដ។ ក្រមនេះកំណត់អំពីការរំពឹងទុកខ្ពស់បំផុតរបស់យើង និងរបៀបដែលទទួលបានជោគជ័យ។

យើងស្នើសុំ ប្រតិបត្តិការទាំងអស់ត្រូវកត់ត្រាទុកឲ្យបានត្រឹមត្រូវស្របតាមគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន និងច្បាប់ និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត។ បុគ្គលិកត្រូវរក្សាទុកកំណត់ត្រាថាត្រឹមត្រូវ ស្មោះត្រង់ និងបង្ហាញពីហេតុការពិត។ អ្នកមិនត្រូវផ្តល់ ឬបញ្ចូលព័ត៌មាននៅក្នុងសៀវភៅ ឬកំណត់ត្រាក្រុមហ៊ុនដែលនាំដល់ ការយល់ច្រឡំ ការយល់ខុស ការផ្តល់ព័ត៌មានមិនត្រឹមត្រូវ ការលុប ឬការ ក្លែងបន្លំ ដោយចេតនានៃប្រតិបត្តិការ ឬលទ្ធផល។

អ្នកត្រូវបានរំពឹងថានឹងសហការយ៉ាងពេញទំហឹងជាមួយសវនករផ្ទៃ ក្នុង និងឯករាជ្យ និងត្រូវរាយការណ៍ភ្លាមៗនូវការសង្ស័យចំពោះការបំពានណាមួយទៅប្រធានគ្រប់គ្រងរបស់អ្នក។

**Q:** ខ្ញុំបានលក់តាមកម្រិតកំណត់របស់ខ្ញុំសម្រាប់ត្រីមាសទីបី។ មិត្តរួមការងារថ្នាក់ផ្នែកគណនេយ្យ ប្រាប់ខ្ញុំថា ខ្ញុំអាចដក យកផ្នែកខ្លះនៃការលក់លើសរបស់ខ្ញុំសម្រាប់ខែបន្ទាប់។ តើការធ្វើដូច្នេះ យ៉ាងម៉េចដែរ? វានៅតែមានចំនួនចំណូលដូចគ្នាសម្រាប់ប្រចាំឆ្នាំ។

**A:** វាមិនអាចទទួលយកបានទេ។ ការរក្សាទុកភាពត្រឹមត្រូវ និងសុចរិតនៃប្រភេទចំណូលទាំងអស់មិនអាចសម្របសម្រួលបានទេ ពីព្រោះវាអាចប៉ះពាល់ដល់ការសម្រេចរបស់ថ្នាក់ដឹកនាំទាក់ទងនឹងអាជីវកម្ម។

> មិនត្រូវធ្វើអោយមានការយល់ច្រឡំ យល់ខុស លុប ឬបំលែងធាតុពិតនៃប្រតិបត្តិការ ឬលទ្ធផលឡើយ



# ធ្វើរឿងដែលត្រឹមត្រូវ

នៅពេលដែលZuellig Pharma ឈានជិតដល់សតវត្សរ៍ទី ២ យើងទទួលស្គាល់នូវអ្វីដែលនាំឱ្យយើងឈានមុខគេក្នុងការដឹកនាំនិងថែរក្សាសុខភាពបច្ចុប្បន្ន៖ ការប្តេជ្ញាចិត្តឥតឈប់ឈរ ដើម្បីធ្វើអ្វីដែលត្រឹមត្រូវសម្រាប់និយោជិកអតិថិជន សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀត។

គុណតម្លៃដ៏សំខាន់នៃសេចក្តីថ្លៃថ្នូរឥតឈប់ឈរ នៃរាល់ទំនាក់ទំនងដែលយើងមាន និងសកម្មភាពដែលយើងធ្វើគឺជាពន្លឺដឹកនាំមួយចំពោះអ្វីគ្រប់យ៉ាងដែលយើងធ្វើ។ ចូរប្រើក្រមសីលធម៌នេះ ដើម្បីជួយអ្នកក្នុងការធ្វើការសម្រេចចិត្តត្រឹមត្រូវ។ នៅពេលណាដែលមានការសង្ស័យ ឬមិនប្រាកដក្នុងអ្វីដែលត្រូវធ្វើ សូមប្រើធនធានដែលមានក្នុងក្រមសីលធម៌ ដើម្បីជួយអ្នកក្នុងការរុករកភាពមិនច្បាស់លាស់។

កន្លែងណាដែលយើងស្ថិតនៅ យើងធ្វើប្រតិបត្តិការជាក្រុម ដែលជាក្រុម Zuellig Pharma។ យើងប្រឈមនឹងឧបសគ្គរបស់យើង ជំនះឧបសគ្គ និងអបអរជោគជ័យរបស់យើងទាំងអស់គ្នា។ សហការ និងគាំទ្រគ្នាទៅវិញទៅមក រួមទាំងនិយោជិក អតិថិជន ដៃគូអាជីវកម្ម សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀត។ នោះហើយជារបៀបដែលយើងទទួលជោគជ័យ។



ក្រមសីលធម៌វិជ្ជាជីវៈរបស់សហគ្រាស Zuellig Pharma នេះ ត្រូវបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន Interpharma Investments Ltd ហើយនឹងត្រូវបានអនុវត្តដោយបុគ្គលិកគ្រប់ជាន់ថ្នាក់នៃក្រុមហ៊ុនសាខារបស់សហគ្រាស Zuellig Pharma ទាំងអស់។

កំណែថ្មី ដែលធ្វើឡើងនា ថ្ងៃទី១ ខែមីនាឆ្នាំ ២០២១ នឹងជំនួសរាល់កំណែចាស់ៗដែលមានស្រាប់។

ក្រមសីលធម៌វិជ្ជាជីវៈនេះធ្វើនៅខែតុលា ឆ្នាំ 2014 ជាសំណើថ្មី ដែលនឹងជំនួសរាល់ក្រមមុនៗ។

## ការត្រួតពិនិត្យកំណែ

| | |
|---|---|
| **កំណែលើកទី ១** | ខែមករាឆ្នាំ ២០១០ |
| **កំណែលើកទី ២** | ខែតុលាឆ្នាំ ២០១៤ |
| **កំណែលើកទី ៣** | ថ្ងៃទី ១២ ខែមិថុនាឆ្នាំ ២០១៥ |
| **កំណែលើកទី ៤** | ថ្ងៃទី ០១ ខែមីនាឆ្នាំ ២០២១ |

រាល់ចម្ងល់ ទាក់ទងទៅនឹងភាពមិនស្របគ្នា រវាងបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ក្នុងស្រុក អ្នកគួរតែធ្វើការរាយការណ៍ទៅកាន់ មន្ត្រីផ្នែកប្រតិបត្តិតាមរបស់អ្នក ឬទាក់ទងមក **hellocompliance@zuelligpharma.com** លើសំណួររបស់អ្នក។

ការបកប្រែក្រមនេះ ត្រូវបានរៀបចំសម្រាប់និយោជិករបស់យើង។ ទោះជាយ៉ាងណាក៏ដោយ សូមកត់សម្គាល់ថាក្នុងករណីមានភាពមិនច្បាស់លាស់ ឬស្រពិចស្រពិលណាមួយ សូមត្រលប់ទៅមើលក្រមនេះជាភាសាអង់គ្លេស។

ZUELLIG PHARMA

making healthcare more accessible